CSC
ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានភាគូលិក
ទូរស័ព្ទ: ០២៣ ២២៤ ១២០

# អ្នកនាំសារ
The Messenger

០៥

ឆ្នាំទី១ ថ្ងៃទី០១-៣១ ធ្នូ ២០០៧- ច្បាប់អនុញ្ញាតរបស់ក្រសួងព័ត៌មានលេខ ១៨៣ ពមប្រក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០០៧

## មាតិកាសំខាន់ៗ



សម្ពោធការិយាល័យសង្គមកិច្ចថ្មីពីអង្គការ JSC
ទំព័រ ៣



ប្រពៃណីនៃការធ្វើអំបុកខ្មែរ
ទំព័រ ៤

អប់រំកុមារតូចៗតាមរយៈការនិទានរឿង
ទំព័រ ៩

# “គ្រីស្តម៉ាស” ជាឱកាសចែកអំណោយគ្នាទៅវិញទៅមក



ទំព័រទី៦...





យានដ្ឋាន For you
for you Garage
មានទទួលជួសជុលរថយន្តគ្រប់ប្រភេទ
All Kinds of Repairing Services
សូមមេត្តាជួយផ្តល់ឱកាសដល់យុវជនក្រីក្រដែលគ្មានលទ្ធភាពទទួលការអប់រំនៅសាលា។ សូមអរគុណ!
Tell: 012 377 460 E-mail: philong2007@gmail.com
អាសយដ្ឋាន៖ ផ្លូវជាតិលេខ ៥ គីឡូម៉ែត្រលេខ ៨

កម្មវិធីវិទ្យុ



អេម៉ានូអែល សំឡេងពីព្រះសហគមន៍កាតូលិក !
ភ្នំពេញ : FM 99.5 Mhz ម៉ោង ៧:០០-៧:៣០ រាល់យប់ថ្ងៃសៅរ៍ ។
បាត់ដំបង : FM 91.0 Mhz ម៉ោង ៧:៣០-៨:០០ រាល់យប់ថ្ងៃសៅរ៍ ។
កំពង់ធំ : FM 107.3 Mhz ម៉ោង ៥:៣០-៦:០០ រាល់ល្ងាចថ្ងៃសៅរ៍ ។
កំពង់ចាម : FM 100.5 Mhz ម៉ោង ៦:៣០-៧:០០ យប់ថ្ងៃអាទិត្យ ។
ក្រុងព្រះសីហនុ: FM100.5 Mhz ម៉ោង៧:៣០-៨:០០ យប់ថ្ងៃសៅរ៍ ។

## វិចារណកថា

# សួស្ដីបុណ្យព្រះយេស៊ូប្រសូត បុណ្យណូអែល ឬ Christmas


Photo: P. Samphy

ប្រសិនបើបងប្អូននៅទីក្រុង បងប្អូនមុខជានឹងឃើញផ្កាយធំៗធ្វើពីក្រដាសចម្រុះពណ៌ និងចាំងចែងពន្លឺយ៉ាងស្អាត មានតាំងផ្សាយពាណិជ្ជកម្ម មានអញ្ជើញគ្នាឱ្យទៅពិសាអាហារយ៉ាងឆ្ងាញ់នៅកន្លែងណាមួយ-ល-។ នៅហាងខ្លះ មានតាំងតុក្កតា តាចាស់ម្នាក់ ពុកមាត់វែង អាវពណ៌ក្រហម មួកក្រហមវែង ហៅថាតាណូអែល។ មនុស្សជាច្រើនយល់ច្រឡំដោយស្មានថា បុណ្យណូអែលគ្រាន់តែជាបុណ្យសប្បាយ ចូលឆ្នាំអឺរ៉ុប ឬក៏ជារដូវជូនពរគ្នាទៅវិញទៅមកប៉ុណ្ណោះ។ តាមពិត យើងជាគ្រីស្ដបរិស័ទមិនពេញចិត្តនឹងអ្វីទាំងនេះសោះ ពីព្រោះអ្វីទាំងនេះហូរចេញមកពីទំនៀមទម្លាប់អ្នកគោរពព្រះអាទិត្យ ឬម្ចាស់ទឹក ម្ចាស់ដីរស់នៅទ្វីបខាងជើងតាំងពីបុរាណមក គឺមិនជាប់ទាក់ទងនឹងជំនឿនៃគ្រីស្ដសាសនាយើងឡើយ។

នៅថ្ងៃ២៤-២៥ ខែធ្នូ យើងជាគ្រីស្ដបរិស័ទនាំគ្នាធ្វើបុណ្យរំឭកថ្ងៃព្រះយេស៊ូប្រសូតនៅដើមនៃគ្រីស្ដសករាជ។ បុណ្យណូអែលមកពីពាក្យឡាតាំង មានន័យថា "កំណើត"។ ទោះបីក្នុងគម្ពីរគ្មានចែងអំពីថ្ងៃព្រះយេស៊ូប្រសូតក្ដី ក៏គ្រីស្ដបរិស័ទពីដើមសន្មតយកថ្ងៃទី២៥ ខែធ្នូ ជាថ្ងៃខួបកំណើតព្រះអង្គដើម្បីគោរពព្រះអង្គទុកជាពន្លឺបំភ្លឺលោក។ នៅថ្ងៃបុណ្យនោះ យើងជាគ្រីស្ដបរិស័ទគោរពព្រះយេស៊ូទុកជាព្រះគ្រីស្ដ និងជាព្រះអម្ចាស់តាំងពីកំណើត។

ដោយព្រះជាម្ចាស់ប្រសូតមកជាមនុស្សដូចយើង មនុស្សគ្រប់ៗរូបមានតម្លៃដ៏ថ្លៃថ្នូរ ព្រោះសុទ្ធតែជារូបតំណាងរបស់ព្រះអង្គ។ នេះជាគ្រឹះនៃសិទ្ធិមនុស្ស។ ទោះបីអ្នកក្រីក្រគោកយ៉ាក គ្មានសម្លៀកបំពាក់ មនុស្សល្ងង់ ឬអ្នកកើតអេដស៍ក្ដី សុទ្ធតែមានតម្លៃដ៏ថ្លៃថ្នូរពីព្រោះគេក៏ជាបុត្រធីតានៃព្រះជាម្ចាស់។

ក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូត បើយើងមានបំណងចង់គោរពព្រះយេស៊ូយ៉ាងពិតប្រាកដ យើងត្រូវតែនឹកគិតដល់អ្នកដែលសង្គមលះបង់ចោល ជួយអ្នកក្រីក្រដោយសុទ្ធចិត្ត យកចិត្តទុកដាក់ស្រុះស្រួលជាមួយអ្នកដែលមានបញ្ហានឹងយើង-ល- ដោយជឿថា នៅពេលយើងគោរពមនុស្សម្នាក់ យើងពិតជាបានគោរពព្រះយេស៊ូដែលប្រសូតមកជាមនុស្សដូចយើងដែរ។ យើងត្រូវនឹកដល់ពាក្យរបស់ចាស់បុរាណថា : "ព្រះជាម្ចាស់ប្រសូតជាមនុស្សដើម្បីឱ្យមនុស្សកើតជាព្រះជាម្ចាស់វិញ"។

សួស្ដីបុណ្យព្រះយេស៊ូប្រសូត !

**លោកបូជាចារ្យហ្វ្រង់ស្វ័រ ប៉ុងស្វដ៏**

## រូបភាព

# តើមានរូបភាពអ្វីសំខាន់សម្រាប់លេខនេះ?








*នៅឆ្នាំនេះ ព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប អកអំបុក សំពះព្រះខែ បានប្រារព្ធធ្វើឡើង នាថ្ងៃទី ២៣-២៤-២៥ វិច្ឆិកា ក្រោមព្រះរាជអធិបតីភាព នៃព្រះករុណា ព្រះបាទសម្ដេច ព្រះបរមនាថ នរោត្ដម សីហមុនី ព្រះមហាក្សត្រកម្ពុជា។ ទូកចូលរួមប្រកួតឆ្នាំនេះ មានចំនួន២១៧គូ ក្នុងនោះមានទូកអុំខ្នាតអន្តរជាតិ៩គូ ទូកអុំបុរសខ្នាតអន្តរជាតិ១៥៤គូ ទូកចែវនារី៣គូ ទូកចែវបុរស ២៥គូ និងទូកពិសេស៣០គូ ក្រៅពីនេះនៅមានការប្រណាំងទូកប្រពៃណីខ្នាតអន្តរជាតិ "អាស៊ាន" ចំនួន ៩ទៀត ដែលមានទូក កម្ពុជា វៀតណាម ថៃ ម៉ាឡេស៊ី ឥណ្ឌូណេស៊ី ឡាវ ហ្វីលីពីន ប្រ៊ុយណេ និងសាំងហ្គាពួរ។ ចំណែកប្រទីបមាន៨ គឺប្រទីបព្រះបរមរាជវាំង ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និងក្រសួងទេសចរណ៍។*



*ទិដ្ឋភាពនៃពិធីអុំទូកនៅលើដងស្ទឹងខេត្តសៀមរាប ដែលប្រារព្ធធ្វើឡើងស្របពេលគ្នានឹងព្រះរាជពិធីបុណ្យអុំទូកអកអំបុកសំពះព្រះខែ នៅរាជធានីភ្នំពេញកាលពីខែវិច្ឆិកា កន្លងទៅ។*

Photographed by L. Samphors; L. Sovanna & Pascal. R



## ព័ត៌មាន

# សមិទ្ធផលថ្មីរបស់សមាគមសាមគ្គីកសិករក្រីក្រ អង្គការជេអេសស៊ី

បងស្រី ដឺនីស ជានាយិកាអង្គការជេអេសស៊ី និងឯកឧត្ដម សយ ស៊ីផុន រដ្ឋលេខាធិការនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅព្រឹកថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧កន្លងទៅ បានអញ្ជើញចូលរួម ជាអធិបតីភាព ក្នុងពិធីសម្ពោធអគារការិយាល័យមួយ ស្ថិតនៅក្នុងសាលាស្រុកអង្គស្នួល ខេត្តកណ្ដាល ។

ដោយមើលឃើញអគារការិយាល័យចាស់មានសភាពទ្រុឌទ្រោម និងមានការស្នើសុំពីសំណាក់លោកអភិបាលស្រុក សមាគមសាមគ្គីកសិករក្រីក្ររបស់អង្គការជេអេសស៊ី បានជួយសាងសង់នូវអគារការិយាល័យមួយខ្នង ដោយចំណាយថវិកាផ្ទាល់ខ្លួននៃសមាគមសាមគ្គីកសិករក្រីក្រ ១៧៨ សមាគម និងក៏មានការចូលរួមគាំទ្រអំពីអង្គការជេអេសស៊ី នៅក្នុងស្រុកអង្គស្នួលផងដែរ ។

តំណាងឱ្យសមាគមសាមគ្គីកសិករក្រីក្រ អ្នកស្រីខុង ណារី បានសំណូមពរឱ្យការប្រើប្រាស់អគារនេះ មានប្រយោជន៍ ក្នុងការទំនាក់ទំនងការងារផ្សេងៗជាមួយនិងបងប្អូនប្រជាជន មានជនពិការ អ្នកបាត់បង់សមត្ថភាពពលកម្ម គ្រួសារយោធិនពលី និងអ្នកចូលនិវត្តន៍-ល-។

មានប្រសាសន៍នៅក្នុងឱកាសនោះ បងស្រីដឺនីសមានចំណាប់អារម្មណ៍ថា បងស្រី មានបំណងចង់ឱ្យអង្គការជេអេសស៊ី បន្តស្ថិតនៅប្រទេសកម្ពុជាចំនួន ១០ឆ្នាំទៅមុខទៀត ។ ក្នុងនោះបងស្រីចង់ឃើញប្រជាជនខ្មែរមានសន្តិភាពជាដរាប ដោយមានការគោរពជីវិតមនុស្សទាំងអស់ និងចេះដោះស្រាយជម្លោះដោយមិនប្រើអំពើហិង្សា ។បងស្រីចង់ឱ្យប្រជាជនចេះគោរពស្រឡាញ់គ្នា អត់អោនឱ្យគ្នាទៅវិញទៅមក អ្នកក្រីក្រ អ្នកមានជីវភាពធូរធា និងមនុស្សទាំងអស់ ចេះគោរពសិទ្ធិរបស់ជនពិការ ជាពិសេសគឺចង់ឃើញកុមារទទួលបានការអប់រំ និងប្រជាជនមានសុខភាពល្អ ។

ចំណែកឯកឧត្ដមសយ ស៊ីផុន ក៏បានថ្លែង នៅក្នុងឱកាសនោះដែរថា អគារការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានេះ មានអត្ថប្រយោជន៍ខ្លាំងណាស់ពីព្រោះជួយឱ្យមន្ត្រីសាលាស្រុកមានកន្លែងធ្វើការមួយសមរម្យ រួមចំណែកសំដៅបម្រើដល់ផលប្រយោជន៍នៃប្រជាជន និងអាចឆ្លើយតបតាមសំណូមពរគាត់ ។ កិច្ចការទាំងនេះ គឺបានបង្ហាញឱ្យឃើញនូវកិច្ចខិតខំមួយរបស់អង្គការ ជេអេសស៊ី ក្នុងចំណោមកិច្ចការជាច្រើនដែលអង្គការសម្រេចបាននាពេលកន្លងមក ។

សូមបញ្ជាក់ផងដែរថា សំណង់អគារការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានេះ មានបណ្ដោយ១០ម៉ែត្រ ទទឹង៨ម៉ែត្រ និងកម្ពស់ ៦,៨ម៉ែត្រ ដែលចំណាយថវិកាចំនួន ១៣ ៣៩៩ ដុល្លារ ពីសមាគមសាមគ្គីកសិករក្រីក្រ ។ ចំណែកអង្គការជេអេសស៊ី ក៏បានបំពាក់កុំព្យូទ័រមួយកំប្លេ ម៉ាស៊ីនព្រីនធើមួយ គ្រឿងសង្ហារិម មានតុកៅអីការិយាល័យ តុកៅអីកុំព្យូទ័រ តុពីរ កៅអីវែង ៤ ទូឯកសារ១ ចំណាយថវិកាអស់ ១ ១៣១ ដុល្លារ ហើយសរុបថវិកាទាំងអស់ គឺ១៤៥៣០ដុល្លារ ។

**ឡុង សម្ផស្ស**



អគារសង្គមកិច្ចថ្មី

Photo: L. Samphors


Photo: HIB

ច្បាប់

# ច្បាប់ ! ចរាចរណ៍ផ្លូវគោក

**សេដ្ឋកិច្ចសង្គមកាន់តែរីកចម្រើនទៅមុខ ចំនួនប្រជាជន និងការប្រើប្រាស់ផ្លូវថ្នល់កើនមិនឈប់ឈរ ដែលធ្វើឱ្យបញ្ហាចរាចរណ៍ចោទជាបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរ។ ដើម្បីចូលរួមចំណែកកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ អ្នកនាំសារ សូមចុះផ្សាយច្បាប់ស្ដីពីចរាចរណ៍ផ្លូវគោកនៃព្រះរាជាណាចក្រកម្ពុជាដូចតទៅ :**

ពាក្យថា **ទម្ងន់សរុបអនុញ្ញាតអតិបរមារបស់យាន** គឺជាផលបូកទម្ងន់ទទេរបស់យានជាមួយនឹងទម្ងន់មនុស្ស និងទម្ងន់ផ្ទុកទំនិញ។ បើសិនជាយានមានសណ្ដោង ទម្ងន់សរុបអនុញ្ញាតអតិបរមារបស់យាន ជាផលបូកនៃទម្ងន់សរុបអតិបរមារបស់យាននីមួយៗ

ពាក្យថា **ទម្ងន់សរុបជាក់ស្ដែងរបស់យាន** ជាផលបូកទម្ងន់ទទេរបស់យានជាមួយនឹងទម្ងន់ផ្ទុកមនុស្ស និងទម្ងន់ផ្ទុកទំនិញជាក់ស្ដែង

ពាក្យថា **រ៉ឺម៉ក** គឺជាយានសម្រាប់ផ្ទុកជាមួយរថយន្ត

ពាក្យថា **សឺមីរ៉ឺម៉ក** គឺជាយានសម្រាប់ផ្ទុកជាប់នឹងក្បាលរថយន្តសណ្ដោង ។

## ជំពូកទី ២
### សញ្ញាចរាចរណ៍

**មាត្រា ៦.-**

សញ្ញាចរាចរណ៍រួមមានផ្លាកសញ្ញាចរាចរណ៍នៅតាមផ្លូវ ភ្លើងសញ្ញាចរាចរណ៍ គំនូសសញ្ញាចរាចរណ៍នៅលើផ្លូវ សញ្ញាបញ្ជារបស់ភ្នាក់ងារចរាចរណ៍ និងសញ្ញាផ្សេងៗទៀត ។

ផ្លាកសញ្ញាចរាចរណ៍ ភ្លើងសញ្ញាចរាចរណ៍ និងគំនូសសញ្ញាចរាចរណ៍នៅលើផ្លូវ ត្រូវរៀបចំជាប្រព័ន្ធទាក់ទង ស៊ីចង្វាក់គ្នាជាហូរហែ នៅតាមកន្លែងមានសារៈប្រយោជន៍ ដែលធ្វើឱ្យអ្នកប្រើប្រាស់ផ្លូវងាយស្រួលមើលឃើញ ។

សញ្ញាគ្រោះថ្នាក់នៅតាមដងផ្លូវ ដែលមានលក្ខណៈមិនអចិន្ត្រៃយ៍ ត្រូវដាក់ក្នុងចម្ងាយសមស្របល្មមគ្រប់គ្រាន់ តាមប្រភេទផ្លូវចំណាត់ថ្នាក់ផ្លូវ និងស្ថានភាពផ្លូវដែលអាចធ្វើឱ្យអ្នកបើកបរមានស្មារតីប្រុងប្រយ័ត្នជាមុនបាន ។

**អ្នកនាំសារ**

December-2007.qxd 12/18/2007 3:54 PM Page 4



**អំបុកជាចំណីដ៏ប្រពៃរបស់ខ្មែរក្នុងរដូវច្រូតកាត់ដើមដៃ ហើយជាអាហារប្រពៃណីមួយតាំងពីបុរាណកាលមក ដែលប្រជាជនខ្មែរបានសម្រិតសម្រាំងយ៉ាងពិសេសសម្រាប់ប្រារព្ធក្នុងពិធីអកអំបុកសំពះព្រះខែ។ ស្រូវត្រូវបានយកមកលីង រួចដាក់ក្នុងត្បាល់ដាល់ឱ្យសំប៉ែត រួចហើយថ្ងៃទទួលទានបានច្រើនយ៉ាងតាមការចូលចិត្ត។**

# វិធីធ្វើអំបុក



Photo: L. Samphors

នាពេលបច្ចុប្បន្ននេះ គេកម្រនឹងបានឃើញអំពីរបៀបធ្វើអំបុកនេះណាស់ ដោយគេច្រើនតែឃើញអំបុកដែលគេធ្វើរួចហើយ លក់នៅតាមទីផ្សារប៉ុណ្ណោះ ។

**តើរបៀបធ្វើអំបុកមានដូចម្តេចខ្លះ ?**

កំពុងលីងស្រូវធ្វើអំបុកដើម្បីបង្ហាញភ្ញៀវក្នុងពិធីសិប្បសាលា ស្តីពីរបៀបធ្វើអំបុក នៅឯមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន អ្នកស្រីអួន ឡុង អាយុ៥៩ឆ្នាំ ដែលរស់នៅភូមិសំរោងរស្មី ឃុំអង្គពពេល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ បានរៀបរាប់ពីរបៀបធ្វើអំបុកថា តាមធម្មតា អំបុក គឺគេច្រើនយកស្រូវដែលទើបច្រូតហើយថ្មីៗមកធ្វើព្រោះមានក្លិនក្រអូបប្រហើរ និងសាច់អំបុកឈ្ងុយទន់ល្អិត ។ គេអាចយកស្រូវចាស់មកធ្វើបានដែរ ។ប៉ុន្តែត្រូវយកទៅត្រាំទឹកជាមុនសិន ។ ការលីងអំបុក គេប្រើអុស ឬធ្យូងបានដូចគ្នា តែត្រូវថៃភ្លើងឱ្យក្តៅល្មម ។ ប្រសិនបើភ្លើងក្តៅពេក គ្រាប់ស្រូវឆ្អិនមិនសព្វហើយឆាប់ផ្ទុះ ជួនកាលទៅជាខ្លោច ។ នៅពេលលីងស្រូវ ត្រូវដាក់ម្តងមួយក្តាប់ៗ ឬកន្លះកូនចានទើបបានល្អ ។ គេពុំអាចកំណត់នាទីក្នុងការលីងនោះបានឡើយ ។ នៅពេលលីង គឺត្រូវកូរវាសឱ្យរហ័ស ត្រូវពិនិត្យមើលទៅតាមគ្រាប់ស្រូវ ដែលកំពុងលីង ឱ្យឆ្អិនសព្វល្អ ពុំទុកឱ្យផ្ទុះទាល់តែអស់នោះទេ ។ បើទុកស្រូវឱ្យផ្ទុះអស់ វាទៅជាលាជ ដែលពេលបុកអាចម៉ត់ទៅជាម្សៅ ដែលហៅថា ផ្អួល ។ វិធីនៃការដាល់អំបុក ត្រូវពិនិត្យទៅតាមប្រភេទស្រូវ ។ នៅពេលលីងស្រូវ រួចត្រូវចាក់ស្រូវចូលទៅក្នុងត្បាល់ ។ អ្នកដាល់អំបុកត្រូវដឹងហើយប៉ាន់ទម្ងន់ដៃ ឱ្យទាន់ពេលស្រូវកំពុងតែនៅកម្តៅ ដែលអាចសំប៉ែតទៅបាន ។ ចំពោះស្រូវខ្សាយ គឺជាប្រភេទអង្កររឹង ពេលបុកត្រូវសង្កត់ទម្ងន់ដៃ ឱ្យខ្លាំងអំពីដំបូងដើម្បីឱ្យសាច់អង្ករសំប៉ែតល្អ ។ តែចំពោះស្រូវដំណើបវិញ ត្រូវបុកបន្ធូរដៃពីដំបូងព្រោះជាប្រភេទអង្ករទន់ បើសង្កត់ធ្ងន់ដៃពីដំបូង ធ្វើឱ្យសាច់អង្ករក្តាំងស្អិត ជាប់គ្នាជាមួយស្រូវ ។ ដូច្នេះអ្នកកាន់ឈើឆ្កៀស ត្រូវរហ័សដៃកាយឱ្យសព្វត្រឡប់បំបែកស្រូវដែលស្អិតចូលគ្នានោះឱ្យរាយចេញពីគ្នាវិញទើបសំណកស្រូវជាប់នោះខ្ទាតចេញអស់បាន ។ នៅពេលបុករួចហើយ គេយកទៅរែង អុំ សំអាតឱ្យអស់អង្កាម និងកន្ទក់ចេញសិន នោះទើបជាការស្រេច និងបានជាអំបុកដែលមានរសជាតិឈ្ងុយឆ្ងាញ់ ។ អ្នកស្រីព្រំ ស៊ីសាផាន្នា ប្រធានគ្រប់គ្រងកម្មវិធីទំនាក់ទំនងវប្បធម៌នៃមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន បានបញ្ជាក់ពីគោលបំណងសិប្បសាលានេះថា : "ការរៀបចំសិប្បសាលានេះឡើង ក្នុងគោលបំណងបង្ហាញអំពីប្រពៃណីខ្មែរដ៏យូរលង់ ដែលកូនខ្មែរភាគច្រើនបានបំភ្លេចចោល ។" អ្នកស្រីបន្តទៀតថា: "កម្មវិធីថ្ងៃនេះចង់បញ្ជាក់ឱ្យយើងមើលឃើញនូវតម្លៃផលិតផលរបស់ខ្មែរយើងផង និងចង់សិក្សា ឱ្យឃើញផងដែរថា តើវត្ថុធាតុដើមអ្វីខ្លះ? ដែលគេយកមក ដើម្បីធ្វើអំបុកឱ្យមានរសជាតិឆ្ងាញ់នោះផងដែរ ។

**ឡុង សម្ផស្ស**

### របៀបនៃការជ្រើសរើសស្រូវ

**ស្រូវធ្វើអំបុក គេយកស្រូវនៅមានពណ៌បៃតងមិនទាន់ទុំញ៉ោះពេកទេ ជាប្រភេទស្រូវទុំស្លាបសេក ដូចជាប្រភេទស្រូវខ្សាយ ឬស្រូវដំណើបដែលធ្វើបានដូចគ្នា។ ក្នុងចំណោមស្រូវដែលមាននៅស្រុកខ្មែរយើង គេច្រើនតែនិយមធ្វើស្រូវដំណើបឆ្នាល់ និងស្រូវផ្កាម្លិះ ព្រោះថានៅពេលទៅជាអំបុកហើយ វាមានរសជាតិឆ្ងាញ់ សាច់អំបុកទន់រមួត ព្រមទាំងមានពណ៌សល្អផង។**



# ដាំឈើត្រប់បែក

**ត្របែកគឺជាប្រភេទផ្លែឈើម្យ៉ាង ដែលជំនួយច្រើនដល់សុខភាព និងរូបសម្រស់។ ម្យ៉ាងវិញទៀតដើមត្របែកនេះមានដុះច្រើនស្ទើរគ្រប់ទីកន្លែង និងពិសេសក៏មាននៅគ្រប់រដូវផងដែរ។ ការដាំដើមត្របែកមិនមែនងាយស្រួល ហើយក៏មិនមែនពិបាកណាស់ណាដែរ។ ខាងក្រោមនេះគឺជារបៀបដាំឱ្យទទួលបានផលល្អ។**


Photo: T. Yort
ដាំត្របែកដោយបច្ចេកទេសនឹងទទួលផលច្រើន

**ការត្រៀមពូជដាំ និងការបណ្តុះគ្រាប់**

យើងជ្រើសរើសពូជដែលមានផ្លែមូល ព្រោះសំបូរផ្លែ និងផ្តល់ទិន្នផលខ្ពស់ ។ យើងយកផ្លែទុំស្រគៀល ចិតសំបកចេញ ដោយទុកតែគ្រាប់ជាប់សាច់ រួចច្រកចូលក្នុងថង់ប្លាស្ទិច រក្សាទុកពីមួយថ្ងៃ ទៅមួយថ្ងៃកន្លះដើម្បីឱ្យវាហប់ ឆាប់រលួយ ។ បន្ទាប់មក យើងច្របាច់វាលាងទឹកឱ្យបានស្អាត ឱ្យសល់តែគ្រាប់ រួចទើបយកទៅហាលថ្ងៃឱ្យស្ងួត ( ពីម៉ោង៧ ដល់៩ព្រឹក) ។ គ្រាប់ត្របែកត្រូវបណ្តុះលើរានដែលលាយដី ១០ភាគ ជាមួយលាមកសត្វ ៣ភាគ និងផេះអង្កាម ៣ភាគ ច្របល់ចូលគ្នាឱ្យសព្វ ។ យើងរោយគ្រាប់ត្របែកលើរាន គឺលៃយ៉ាងណាកុំឱ្យក្រាស់ពេក រួចយកជីលាមកសត្វទៅរោយពីលើគ្រាប់ស្តើងៗ បន្ទាប់មក យកកំទេចចំបើងរោយពីលើថែមទៀត ។ ក្រោយពីបណ្តុះគ្រាប់ហើយស្រោចទឹកឱ្យជោក គឺ២ដងក្នុង១ថ្ងៃ ។ នៅពេលត្របែកមានអាយុ៣០ថ្ងៃ អាចគាស់កូនយកទៅផ្សាំ នៅក្នុងថង់មួយសាទៀតរហូតដល់ត្របែក កម្ពស់៧-១០សង់ទីម៉ែត្រ ទើបផ្ទេរយកទៅដាំនៅក្នុងចំការវិញ ។

**ផ្សាំកូនត្របែក**

យើងរៀបចំដីដាក់ក្នុងថង់ ដែលមានដីមានជីជាតិ ១០ភាគ ហាលថ្ងៃឱ្យស្ងួតល្អ លាយជាមួយផេះអង្កាម ៥ភាគ ច្របល់បញ្ចូលគ្នាឱ្យសព្វ ។ កូនត្របែកដែលយកផ្សាំ ត្រូវកាត់ចុងឫស ប្រវែង១ភាគ៥ចោល ។ ពេលផ្សាំ យើងត្រូវដាក់នៅក្រោមម្លប់ឈើ ។ បន្ទាប់មកស្រោចទឹក ១ថ្ងៃ ៣ដង ពេលត្របែកដុះត្រួយថ្មី បន្ថយការស្រោចទឹក ក្នុង ១ថ្ងៃ ២ដងវិញ ។ បន្ទាប់ពីដុះត្រួយថ្មីហើយ យើងយកកូនត្របែកទៅដាក់ក្រោមកំដៅថ្ងៃវិញដើម្បីឱ្យវាលូតលាស់ល្អ ។ពេលត្របែកមានកម្ពស់ ៣០ស.ម យើងអាចយកទៅដាំក្នុងចំការបាន ។

**ការរៀបចំរណ្តៅ និងការដាំ**

យើងដាំលើដីដែលមិនជាំទឹក ។ យើងត្រូវតែភ្ជួរដី ឱ្យបាន២-៣ដង ហើយហាលដីរយៈពេល១ ទៅ ២សប្តាហ៍ ទើបជីករណ្តៅដាក់ដាំ ។ រណ្តៅមានទំហំ៤តឹកបួនជ្រុង និងជម្រៅ ៤តឹក ( ទំហំរណ្តៅនេះ គឺសម្រាប់ដីដែលយើងភ្ជួររួច) ។ ចំពោះដីដែលមិនទាន់ភ្ជួរវិញ អាចជីកទំហំ ៦តឹកបួនជ្រុង និងជម្រៅ ៦តឹក ។ ក្រោយពីជីករណ្តៅរួចហាលរណ្តៅចោលរយៈពេល៧-១០ថ្ងៃសិន ទើបប្រមូលជីលាមកសត្វពុកផុយ ឬជីកំប៉ុស្តទៅដាក់នៅក្នុងរណ្តៅដោយហែកថង់ចេញ រួចបុកដីជុំវិញឱ្យណែន ។ មាត់រណ្តៅធ្វើជារាងកំពែង ដើម្បីឱ្យទឹកដក់ក្នុងរណ្តៅ និងម្យ៉ាងដើម្បីឱ្យជីនៅបាតរណ្តៅឆាប់រលួយ ។

**ការថែទាំ**

យើងស្រោចទឹករាល់ ២ថ្ងៃម្តង និងឧស្សាហ៍ក្តិចត្រួយចោល ដើម្បីឱ្យត្របែកអាចបែកមែក និងមានផ្លែច្រើន ។ ក្រៅពីក្តិចត្រួយ ត្រូវដាក់ជីបំប៉ននៅពេលត្របែកជិតចេញផ្កា ។ ដើម្បីរក្សាពណ៌ត្របែកឱ្យបានស្រស់និងគ្មានការបំផ្លាញពីសត្វល្អិត យើងត្រូវយកក្រណាត់ទេសឯកពណ៌សដេរជាថង់ យកជ្រលក់ជាមួយទឹកសាប៊ូ រួចហាលថ្ងៃឱ្យស្ងួត ច្រកផ្លែត្របែកដែលមានទំហំប៉ុនពងទា ។

**ទស្សនាវដ្តីកសិករ លេខ៩៥**

### សិក្សាកសិកម្ម

**ប្រសិនបើប្រិយមិត្តមានបំណងចង់សិក្សាអំពីវិធីសាស្ត្រ ឬបច្ចេកទេសខាងកសិកម្មគ្រប់ប្រភេទ ដូចជាការចិញ្ចឹមសត្វ ឬដាំដំណាំផ្សេងៗ គឺមានបង្រៀននៅមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ហៅសេដាក ឬបុគ្គលិកសេដាកអាចទៅបង្រៀនដល់ទីកន្លែងផ្ទាល់ដោយគិតក្នុងតម្លៃសមរម្យ។ សូមទំនាក់ទំនងទូរស័ព្ទ : ០២៣ ៨៨០ ៩១៦។**



**កន្ទុយថ្លែនគឺជាជំងឺចក្ខុម្យ៉ាង ដែលភាគច្រើនកើតមាននៅទីជនបទនៃប្រទេសកម្ពុជា។ ជំងឺនេះតែងបង្កការរំខានដល់កិច្ចការងារប្រចាំថ្ងៃរបស់ប្រជាកសិករពីព្រោះវាធ្វើឱ្យគំហើញរបស់គាត់ចុះខ្សោយ ឬក៏ធ្ងន់ធ្ងរបំផុតធ្វើឱ្យងងឹតភ្នែក និងមើលលែងឃើញតែម្តង។**

# ភ្នែកកន្ទុយថ្លែន

តាមប្រសាសន៍របស់លោកដោរ សីហា វេជ្ជបណ្ឌិតឯកទេសភ្នែក បានប្រាប់ឱ្យដឹងថា កន្ទុយថ្លែនគឺជាសាច់ដែលដុះចេញពីភ្នាសស្តើងនៃគ្រាប់ភ្នែកផ្នែកពីខាងច្រមុះសំដៅទៅលើកញ្ចក់ភ្នែក ហើយជួនកាល វាក៏កើតមានទាំងសងខាងនៃកញ្ចក់ភ្នែក ។ កន្ទុយថ្លែនច្រើនកើតនៅក្នុងតំបន់ដែលក្តៅ ស្ងួត សំបូរខ្យល់ ឬអាចបណ្តាលមកពីការកកិតរុំារ៉ៃលើគ្រាប់ភ្នែក ។ កាលណាយើងធ្វើការក្រោមកម្តៅថ្ងៃច្រើន ឬពេលភ្នែកយើងត្រូវខ្យល់ក្តៅស្ងួតនៅពេលធ្វើដំណើរ វានឹងធ្វើឱ្យកន្ទុយថ្លែនដុះកើតមានឡើង ។ តួយ៉ាងនៅស្រុកខ្មែរ ជំងឺកន្ទុយថ្លែនច្រើនមានកើតច្រើនចំពោះប្រជាកសិករដោយសារគាត់ធ្វើការនៅវាលស្រែ ត្រូវថ្ងៃ និងត្រូវខ្យល់ច្រើន ។

រោគសញ្ញារបស់ជំងឺកន្ទុយថ្លែន មានដូចជា មានសាច់ដុះគ្របពីលើកញ្ចក់ភ្នែក ។នៅពេលសាច់នោះដុះគ្របលើកូនក្រមុំភ្នែក វានឹងធ្វើឱ្យគំហើញមានការថយចុះ ។ បើយើងពិនិត្យទៅលើគ្រាប់ភ្នែក នឹងឃើញមានភ្នាស់ស្តើងនៃភ្នែកនៅលើកញ្ចក់ភ្នែក និងក៏មានសរសៃឈាមច្រើន ។ ភ្នែកឡើងពណ៌ក្រហមញឹកញាប់ គ្រាន់តែប៉ះខ្យល់ពន្លឺថ្ងៃ ឬសាប៊ូនៅពេលងូតទឹក ក៏ក្រហមហើយ និងឧស្សាហ៍មានហៀរទឹកភ្នែក ។ ភ្នែកមានអាការៈរកាំ ដូចជា មានដីខ្សាច់នៅក្នុងគ្រាប់ភ្នែក ពេលបិទបើកភ្នែកទៅ ដូចជាមានអ្វីទើសៗ ។ នៅពេលដែលជំងឺកន្ទុយថ្លែនវិវត្តយូរៗទៅ សាច់អាចដុះលាតសន្ធឹងទៅដល់កណ្តាលកញ្ចក់ភ្នែក បាំងកូនក្រមុំ ដែលបណ្តាលឱ្យការមើលឃើញថយចុះ ។ សាច់នេះអាចដុះបាំង ដែលមើលតែមកូនក្រមុំមិនឃើញឡើយ ។ កូនក្រមុំរបស់ភ្នែកពណ៌ខ្មៅ និងងាយប្រតិកម្មនឹងពន្លឺ ។ ចំណែកការព្យាបាលវិញ នៅពេលកន្ទុយថ្លែនដុះតិចតួច ជាធម្មតាមិនត្រូវការព្យាបាលទេ ។ ប៉ុន្តែនៅពេលវាដុះជិតដល់កូនក្រមុំភ្នែកហើយ អ្នកជំងឺត្រូវទៅជួបនឹងវេជ្ជបណ្ឌិតជំនាញដើម្បីទទួលការវះកាត់ភ្នែក និងព្យាបាល ។ ជំងឺកន្ទុយថ្លែន គឺកើតលើមនុស្សគ្រប់វ័យទាំងអស់ ពិសេសកើតលើមនុស្សអាយុចាប់ពី៣០ឆ្នាំឡើងទៅ ។

**ជាត សំភី**


Photo: P. Samphy
វេជ្ជបណ្ឌិតដោរ សីហា ឯកទេសភ្នែកនៅមន្ទីរពេទ្យព្រះអង្គឌួង

### ការការពារ

**យើងថែរក្សាភ្នែកដោយប្រើវ៉ែនតាខ្មៅ ការពារពន្លឺថ្ងៃ ឬពេលធ្វើដំណើរដោយទោចក្រយាន ត្រូវពាក់មួកសុវត្ថិភាពដែលអាចការពារខ្យល់ ពន្លឺថ្ងៃ ឬក៏គ្រោះថ្នាក់ចរាចរណ៍ដោយថែមទៀតផងដែរ។**

December-2007.qxd 12/18/2007 3:54 PM Page 6



ចូលមកដល់ខែធ្នូ នៅតាមអគារពាណិជ្ជកម្មទំនើប អាហារដ្ឋាន ហើយនិងបណ្ណាគារក្នុងទីក្រុង មានរៀបចំតុបតែងជាភ្លើងពណ៌ផ្សេងៗ និងមានរៀបចំរូបតុក្កតា លោកតាម្នាក់ ដែលមានពុកមាត់វែងពណ៌ស និងមានសម្លៀកបំពាក់ពណ៌ក្រហម ដែលគេហៅថា "សានតាក្លូស ឬលោកតាណូអែល"។ យុវជនភាគច្រើនកំពុងយល់ច្រឡំថា គ្រីស្តម៉ាសនាថ្ងៃទី២៤-២៥ ខែធ្នូ គ្រាន់តែជាបុណ្យសប្បាយមួយនៅបស្ចិមប្រទេស ដោយនាំគ្នាជប់លៀង និងជូនអំណោយដល់គ្នាទៅវិញទៅមកតែប៉ុណ្ណោះ។ ចំពោះគ្រីស្តបរិស័ទ បុណ្យនេះគេប្រារព្ធដើម្បីរំឭកដល់ថ្ងៃកំណើតរបស់ព្រះយេស៊ូដែលបានប្រសូតជាមនុស្សតាមជំនឿរបស់គេ។ គេជូនអំណោយដល់មិត្តភក្តិដោយក្តីស្រឡាញ់ និងមានអំណរសប្បាយតាមជំនឿដែលព្រះជាម្ចាស់បានប្រទានឱ្យ។ តើយុវជនខ្មែរគួរទទួលយកវប្បធម៌នេះយ៉ាងគត្រឹកគគ្រេងដោយគ្រាន់តែយល់ថា នេះជាបុណ្យសប្បាយមួយ ឬយ៉ាងណា ក្នុងពេលដែលខ្មែរយើងមានវប្បធម៌យ៉ាងសម្បូរបែបហើយនោះ?

# "គ្រីស្តម៉ាស" ជាឱកាសចែកអំណោយគ្នាទៅវិញទៅមក



Photo: DR

កាតប៉ុស្តាល់ជូនពរក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូត ឬគ្រីស្តម៉ាស



Photo: DR

**ព្រះយេស៊ូដែលជាព្រះបុត្រារបស់ព្រះជាម្ចាស់យាងចុះមកចាប់កំណើតជាមនុស្ស នៅលើផែនដីនេះ ដើម្បីជួយឱ្យមនុស្សលោកយើងរស់នៅបានប្រកបដោយសុខសន្តិភាព និងសុភមង្គលជានិរន្តរ៍**

ការជះឥទ្ធិពលវប្បធម៌ផ្សេងៗ ចូលប្រទេសមួយដែលកំពុងអភិវឌ្ឍ ឬប្រទេសដែលមានការអភិវឌ្ឍ គឺជាការមួយធម្មតាប៉ុណ្ណោះ។ តែលទ្ធផលល្អ ឬអាក្រក់ អាស្រ័យលើអ្នកដែលទទួលឥទ្ធិពលនោះថា ទទួលយកត្រឹមកម្រិតណា។ ចំនុចនេះនឹងបង្កគ្រោះថ្នាក់ បើអ្នកទទួលនោះទទួលយកទាំងស្រុង ដោយមិនមានការរិះគិតពិចារណា ហើយភ្លេចវប្បធម៌ដ៏ល្អរបស់ខ្លួន។ ប៉ុន្តែនេះក៏ជារឿងល្អប្រពៃដែរ នៅពេលយើងទទួលយកមកដើម្បីលើកស្ទួយ និងអភិវឌ្ឍវប្បធម៌ប្រពៃណី-ទំនៀមទម្លាប់របស់ខ្លួន ឱ្យកាន់តែមានភាពរីកចម្រើនថ្កុំថ្កើងឡើងមួយកម្រិតទៀតនោះ។

**គ្រីស្តម៉ាស ឬណូអែលជាបុណ្យសប្បាយ**

រៀងរាល់ឆ្នាំនៅតាមគ្រឹះស្ថានអប់រំជាច្រើនក្នុងទីក្រុងភ្នំពេញ តែងមានលេងកំសាន្ត បុណ្យគ្រីស្តម៉ាស ដូចជាលេងល្បែងប្តូរអំណោយ (ចាប់កាដូ) ជាដើម ដែលជាចំណាប់អារម្មណ៍របស់សិស្ស ឬនិស្សិតដែលបានមករៀន។ ដោយឡែកនិស្សិតឧត្តមសិក្សា ជួបជុំជាក្រុមដើម្បីជូនអំណោយដល់គ្នាទៅវិញទៅមកតាមកម្មវិធីដែលគេរៀបចំ។ យុវជនម៉ែតវិចិត្រនិស្សិតឆ្នាំទី៣ នៅសកលវិទ្យាល័យឯកជនមួយ បានឱ្យដឹងពីអារម្មណ៍ខ្លួនថា: "នៅថ្ងៃបុណ្យនោះ ខ្ញុំ និងក្រុមមិត្តភក្តិតែងជួបជុំ បរិភោគអាហារជុំរួមគ្នា និងលេងចាប់លេខយកអំណោយផងដែរ"។ និស្សិតរូបនេះបន្តថា អំណោយទាំងនេះគឺជារបស់សមាជិកម្នាក់ៗយកមកដាក់រួមគ្នាដែលជាល្បែងធ្វើឱ្យលោក និងក្រុមមិត្តភក្តិកាន់តែរីករាយ និងស្និទ្ធស្នាលថែមទៀត។

ដោយសារភាពរីកចម្រើននៃបច្ចេកវិទ្យាក្នុងសម័យទំនើបនេះ ធ្វើឱ្យយុវវ័យមានការវង្វេងនឹងសម្ភារៈនិយម និងចូលចិត្តអ្វីដែលថ្មីៗ និងទាន់សម័យ។ យុវនារីលីនដា ដែលជាសិស្សវិទ្យាល័យវត្តកោះ បានសម្តែងអារម្មណ៍ខ្លួនថា: "ណូអែលជាបុណ្យមួយសប្បាយ និងទាន់សម័យ ពីព្រោះមានចម្រៀងពិរោះ និងបរិយាកាស សប្បាយរីករាយ"។ កញ្ញាបញ្ជាក់ទៀតថា មានការលេងចែកអំណោយឱ្យគ្នាទៅវិញទៅមក និងទៅញ៉ាំអាហារជាមួយគ្នាផងដែរ។ កញ្ញាតែងទទួលកាដូជាច្រើនពីមិត្តភក្តិ តែក៏ធ្លាប់ជូនកាដូដល់មិត្តភក្តិជាមួយនឹងពាក្យជូនពរពិរោះៗទៀតផងដែរ។ សម្រាប់ថ្ងៃបុណ្យណូអែលខាងមុខនេះ កញ្ញាបានរៀបចំកាដូរួចជាស្រេចហើយ។

ចំណែកកញ្ញាទុំ ផល្លី សិស្សភាសាអង់គ្លេសក្រៅម៉ោងនៃវិទ្យាស្ថានឯកជនមួយក្នុងក្រុងភ្នំពេញ ចាប់អារម្មណ៍ថា: "ការជូនអំណោយដល់មិត្តភក្តិ ធ្វើឱ្យនាងសប្បាយចិត្ត ជាពិសេសការជូនអំណោយឱ្យមនុស្សដែលនាងស្រឡាញ់"។ ប៉ុន្តែចំពោះអត្ថន័យបុណ្យយ៉ាងណានោះ នាងបញ្ជាក់ថា: "ខ្ញុំមិនដឹងមានន័យយ៉ាងណានោះទេ គ្រាន់តែដឹងថា នេះជាថ្ងៃដែលធ្វើឱ្យចិត្តរីករាយ ជាពិសេសបង្កបរិយា-កាសសប្បាយរួមជាមិត្តភក្តិ"។ នាងគ្រាន់តែមានការសម្គាល់ ដឹងថា មានសានតាក្លូស និងដើមគ្រីស្តម៉ាសប៉ុណ្ណោះ។

សម្រាប់ការទទួលឥទ្ធិពលពីបុណ្យគ្រីស្តម៉ាស របស់យុវវ័យដោយភាពមិនច្បាស់លាស់បែបនេះ ព្រះតេជព្រះគុណលី ហុងលាង ដែលជាសាមណៈសិស្សនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត មានសង្ឃដីកាថា អ្វីដែលជាការប្រព្រឹត្តរបស់យុវជនតែងស្វែងរកការសប្បាយ។ បើយើងពិចារណាទៅ វាមានការប៉ះពាល់ដល់ព្រះពុទ្ធសាសនាខ្មែរយើងដែរ ប៉ុន្តែបើចង់ឱ្យអ្នកដទៃទទួលស្គាល់តម្លៃរបស់ខ្លួនលុះត្រាតែមានសាសនាផ្សេងៗយកមកប្រៀបធៀប និងស្វែងយល់ថា តើសាសនាយើងមានតម្លៃប៉ុណ្ណា ឬក៏មានតែទ្រឹស្តី។ សាមណៈសិស្សរូបនេះបញ្ជាក់ថា នៅក្នុងពុទ្ធសាសនា មានទ្រឹស្តីអប់រំច្រើនណាស់ដើម្បីមនុស្សទាំងឡាយ។ ព្រះអង្គសំណូមពរឱ្យយើងទាំងអស់គ្នាជួយធ្វើយ៉ាងណា ដើម្បីឱ្យយុវជនខ្មែរបានយល់ដោយទូលំទូលាយអំពីព្រះពុទ្ធសាសនារួមជាមួយសាសនាផ្សេងៗ ដោយក្តីស្រឡាញ់ និងសន្តិភាព។ ជាពិសេស យុវជនសូមកុំភ្លេចខ្លួន និងកុំឱ្យឃើញអ្វីដែលមកថ្មី សុទ្ធតែយល់ថា ល្អជានិច្ចនោះ។ ព្រះអង្គសូមអាជ្ញាធរដែលពាក់ព័ន្ធមេត្តាពិនិត្យដោយតឹងរឹង កុំឱ្យមានការធ្វើពិធីបុណ្យនេះនៅតាមសាលាយ៉ាងគគ្រឹកគគ្រេងពេកដែលនាំឱ្យសិស្សានុ-សិស្សមានការយល់ច្រឡំ និងជះឥទ្ធិពលអាក្រក់ដល់ក្មេង។

**សានតាក្លូស**

**នៅពេលបុណ្យណូអែល គេតែងតែដាក់តាំងរូបសន្តាក្លូសគ្រប់ទីកន្លែង។ តើរូបនេះមានប្រភពមកពីណា? សន្តាក្លូសនៅសហរដ្ឋអាមេរិក ត្រូវបានគេគូរឡើងនៅក្នុងសតវត្សទី១៩ អំឡុងឆ្នាំ១៨៦៣ ហើយចុះផ្សាយនៅទំព័រកាសែត "Harpper's Weekly"។ ក្រោយមកត្រូវបានក្រុមហ៊ុនកូកាកូឡាយកទៅឃោសនាផ្សាយផលិតផលរបស់ខ្លួនដោយដាក់សម្លៀកបំពាក់ពណ៌ក្រហមតាមពណ៌កូកាកូឡាវិញ។ ចាប់ពីពេលនោះមក សន្តាក្លូសកាន់តែល្បី។**

**ណូអែលតាមជំនឿគ្រីស្តសាសនា**

លោកយ៉ូហាន អាលបេ មូញ៉ាស បូជាចារ្យព្រះសហគមន៍កាតូលិកសាសនទូតមកពីប្រទេសកូឡុំប៊ី រៀបរាប់អំពីការប្រារព្ធពិធីបុណ្យណូអែលនៅឯស្រុកកំណើតរបស់លោក ដែលគោរពគ្រីស្តសាសនានិកាយកាតូលិកយ៉ាងដូច្នេះថា ណូអែលជាបុណ្យសំខាន់ ដូចបុណ្យចម្លង (បុណ្យដែលព្រះយេស៊ូសុគត និងមានព្រះជន្មរស់ឡើងវិញ) សម្រាប់យើងជាគ្រីស្តបរិស័ទ។ បុណ្យណូអែលសម្រាប់អ្នកខ្លះ ជាឱកាសទទួល និងជូនការដូរឱ្យគ្នាទៅវិញទៅមក។ អ្នកខ្លះឯទៀតបុណ្យណូអែល ជាពេលវេលាឈប់សំរាក ឬជួបជុំគ្រួសារ។ ចំពោះគ្រីស្តបរិស័ទ នេះជាពេលវេលាដ៏ពិសេស ដើម្បីនឹករឭកដល់ព្រះជាម្ចាស់ដែលយាងមកក្នុងលោកជាមនុស្សដូចយើង។ នាពេលបុណ្យណូអែល គេតែងតែរៀបចំគេហដ្ឋាន គឺមានដាក់ភ្លើងពណ៌ជាច្រើន ប៉ុន្តែអ្វីដែលសំខាន់ យើងត្រូវការរៀបចំចិត្តគំនិតរបស់យើងដែរ។ សាសនទូតរូបនេះបន្ថែមថា បុណ្យព្រះយេស៊ូប្រសូត្រ មានន័យថា យើងទទួលអំណរសប្បាយពីព្រះជាម្ចាស់។ ក្នុងទីក្រុង មានរៀបចំភ្លើងពណ៌គ្រប់ប្រភេទ នៅតាមផ្លូវ ក្នុងផ្ទះ និងនៅឯទីសាធារណៈផ្សេងៗនិងមានក្រោលសត្វមួយយ៉ាងធំ ដែលក្នុងនោះមានដាក់រូបព្រះយេស៊ូប្រសូត។ ថ្ងៃបុណ្យនេះ មានមនុស្សជាច្រើនមកពីកន្លែងផ្សេងៗនៅតាមជនបទ និងទីក្រុងផ្សេងៗទៀត មកចូលរួមកម្មវិធីនោះ។ រាល់យប់ មាននូវកម្មវិធីសិល្បៈ សម្តែង របាំ តន្ត្រីចម្រៀងបុណ្យណូអែលក្បែរក្រោលសត្វដែលរៀបចំនោះ ជាពិសេសកន្លែងណាក៏មានលក់ម្ហូបប្រពៃណីរបស់យើងដែរនៅតាមដងផ្លូវនៅក្នុងទីក្រុង។ នៅមុនថ្ងៃបុណ្យណូអែល ៩ថ្ងៃ យើងក៏មានកម្មវិធីអធិ-ដ្ឋានដើម្បីរៀបចំចិត្តគំនិតទទួលព្រះយេស៊ូរួមគ្នា សម្រាប់អ្នកដែលរស់នៅទីក្រុង និងអ្នកដែលរស់នៅឯឆ្ងាយពីទីក្រុង ពួកគេមានពិធីអធិដ្ឋានតាមព្រះវិហាររៀងៗខ្លួន។

ទាក់ទងនឹងវប្បធម៌ទំនៀម-ទម្លាប់ក្នុងថ្ងៃបុណ្យ រួមជាមួយក្មេងៗ បូជាចារ្យរូបនេះបញ្ជាក់ថា កូនក្មេងចូលរួមអធិដ្ឋាននិងរីករាយក្នុងបុណ្យនេះ ដោយជឿថា ពេលយប់មុនថ្ងៃបុណ្យព្រះយេស៊ូប្រសូត ព្រះយេស៊ូនឹងប្រទានឱ្យពួកគេនូវកាដូពិសេសមួយ ព្រោះរៀងរាល់ឆ្នាំ ពួកគេតែងទទួលនូវកាដូអាថ៌កំបាំងពីឪពុកម្តាយដែលធ្វើឱ្យគេភ្ញាក់ផ្អើល ហើយកាដូនេះ ពួកគេតែងគិតថា វាជាការប្រទានផ្ទាល់របស់ព្រះយេស៊ូដល់ពួកគេ។ ដូច្នេះហើយកាដូនាថ្ងៃបុណ្យណូអែលសម្រាប់ពួកគេ មានសារៈសំខាន់ណាស់ ហើយពួកគេតែងសរសេរសំបុត្រមួយ គឺសូមព្រះជាម្ចាស់ប្រទានពរដល់គ្រួសាររបស់គេ និងអ្វីដែលគេចង់បានពីព្រះយេស៊ូក្នុងពេលបុណ្យណូអែលនោះដែរ។ តាមជំនឿរបស់កូនក្មេងនៅប្រទេសខ្ញុំ ពួកគេពុំជឿថាមានសានតាក្លូសដែលផ្តល់អំណរសប្បាយ ឬក៏កាដូដល់ក្មេងៗនោះទេ ប៉ុន្តែពួកគេជឿថា អ្វីដែលពួកគេបានទទួលនេះ មកពីព្រះយេស៊ូផ្ទាល់។ នៅពេលគេធំ ទោះបីជាពួកគេដឹងថាកាដូនេះ ពុំមែនព្រះយេស៊ូប្រទានឱ្យ គឺឪពុកម្តាយរបស់ពួកគេជាអ្នករៀបចំក្តី ក៏ពួកគេជឿថា នេះគឺជាការប្រទានពរ និងអំណរសប្បាយពីព្រះយេស៊ូដូចគ្នា ព្រោះរាល់ទង្វើដែលឪពុកម្តាយបានធ្វើ គឺមកពីព្រះជាម្ចាស់។ ...



Photo: L. Sovanna

បុណ្យព្រះយេស៊ូប្រសូតជាឱកាសមួយជួយពង្រឹងជំនឿគ្រីស្តបរិស័ទ

December-2007.qxd 12/18/2007 3:54 PM Page 8



**. . . ក៏ជាឱកាសកេងចំណេញផ្លូវភេទពីគូសង្សារ**

តាមប្រពៃណី-ទំនៀមទម្លាប់ខ្មែរ បើយើងនិយាយអំពីការរួមភេទរបស់យុវវ័យមុនពេលរៀបការ ជារឿងមួយពិបាកនឹងទទួលយកបានណាស់ ។ ប៉ុន្តែដោយសារការវិវឌ្ឍន៍នៃសង្គមកាន់តែឈានទៅមុខ មនុស្សក៏ជិនណាយនឹងទំនៀមទម្លាប់បូរាណ ។ ចំណែកសីលធម៌របស់យុវជនក៏មានការធ្លាក់ចុះគួរឱ្យព្រួយបារម្ភ ។

តួយ៉ាងយុវជនជួ តារា បាននាំយើងឱ្យស្តាប់នូវរឿងពិតមួយរបស់លោក ។ លោកជាបុគ្គលិករដ្ឋបាលនៃរោងចក្រមួយ នៅជាយក្រុងភ្នំពេញ ពេលនិយាយដល់បុណ្យណូអែល ធ្វើឱ្យយុវជនរូបនេះ នឹកឃើញរឿងរ៉ាវ កាលពី២ឆ្នាំមុន កាលលោកទើបទទួលបានការងារដំបូង ពេលនោះលោកមានទំនាក់ទំនងជាមួយយុវសិស្សម្នាក់ នៅវិទ្យាល័យមួយ ក្នុងក្រុងភ្នំពេញ ជាកូនអ្នកមានជីវភាពសមរម្យ ។ ការទំនាក់ទំនងស្គាល់គ្នាតាមរយៈទូរស័ព្ទ ជួបគ្នាតែ២លើកប៉ុណ្ណោះ លើកទី១ នាពេលបុណ្យអុំទូក លើកទី២ គឺក្នុងថ្ងៃបុណ្យណូអែល ។ ថ្ងៃបុណ្យណូអែល តារាទិញអំណោយជូនឱ្យនាង និងនាំនាងមើលកុន ។ ពេលយប់នាំនាងដើរលេងច្រើនជុំនៅទីក្រុងភ្នំពេញ ចូលឱស្ថជាដើមរហូតយប់រំលងអធ្រាត្រ ។ ពេលនោះពួកគេមានគំនិតត្រូវគ្នា ឈានចូលដល់ការរួមភេទក្នុងសណ្ឋាគារមួយ ។ តារាបានបន្តថា ក្រោយពីរួមភេទជាមួយនាងហើយ គេហាក់ដូចជាតាំងចិត្តក្នុងការទទួលខុសត្រូវ ។ តែបីខែក្រោយមក គេមានការជិនណាយ ហើយឈប់ទាក់ទងគ្នាបន្តទៀត ។ បើនិយាយទៅ តារាហាក់បីដូចជាបានចំណេញដោយបានយល់ព្រមរួមភេទពីដៃគូដោយមិនចាំបាច់ទទួលខុសត្រូវ ។ ប៉ុន្តែតារាបញ្ជាក់ ដោយស្តាយក្រោយថា ជាប្រការមិនសមរម្យឡើយ ព្រោះធ្វើខុសនឹងទំនៀមទម្លាប់របស់ខ្មែរ ។ តារាក៏សូមផ្តាំផ្ញើយុវនារីទាំងអស់ កុំឱ្យភ្លេចខ្លួន និងកុំងាយជឿគេខ្លាំងពេក ។ ទោះបីយើងជឿជាក់ខ្លួនឯងខ្លាំងយ៉ាងណាក៏ដោយ តែដល់ពេលយើងនៅតែពីរនាក់ ពេលនោះ យើងគឺមិនអាចគ្រប់គ្រងខ្លួនយើងបានទេ ។ តើយុវនារីប៉ុន្មានដែលរងគ្រោះ ព្រោះតែអំណោយនៅថ្ងៃបុណ្យណូអែលនេះ? (ជួ តារា ជាឈ្មោះប្រឌិត) ។


Photo: L. Samphors
រូបតាសានតាក្លូសដែលពាណិជ្ជករដាក់មុខហាងទាក់ទាញអតិថិជន

## នំសម្រាប់ណូអែល

ហាងនំអាស៊ី-អឺរ៉ុប ជាហាងនំផលិតនំគ្រប់ប្រភេទជាង១០០មុខ ដើម្បីបម្រើតម្រូវការអតិថិជន។ កញ្ញាលាង រដ្ឋា ជាម្ចាស់ហាង បានឱ្យដឹងថា នាឱកាសបុណ្យណូអែល ចាប់ពីថ្ងៃទី៥ ខែធ្នូ រហូតដល់ថ្ងៃទី៥ ខែមករា ឆ្នាំ ២០០៨ គ្រប់អតិថិជនដែលមកជាវនំ អស់ទឹកប្រាក់ចំនួន ៦ដុល្លារឡើង នឹងទទួលបានវត្ថុអនុស្សាវរីយ៍ចំនួនមួយ។ ចំពោះតម្លៃមានតាមតម្រូវការរបស់ភ្ញៀវ គឺនំមានតម្លៃចាប់ពី ០,៥០ដុល្លាររហូតទៅដល់ ២០០ដុល្លារ។

## អ្នកស្រីគង់ ណារី : "ត្រូវគោរពដល់អ្នកដែលកាន់សាសនា"

អ្នកស្រីគង់ ណារី ដែលជាសាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរ និងទទួលបន្ទុកខាងការបណ្តុះបណ្តាលសិល្បៈនៃវិទ្យាល័យវត្តកោះ ក្រុងភ្នំពេញ បានបញ្ចេញទស្សនៈរបស់អ្នកគ្រូចំពោះការទទួល និងប្រារព្ធពិធីបុណ្យណូអែលរបស់យុវសិស្ស និងនិស្សិតខ្មែរនៅតាមសាលារដ្ឋ និងឯកជននានាយ៉ាងដូច្នេះថា :

ប្រទេសយើងកំពុងទទួលការអភិវឌ្ឍន៍ ហើយរដ្ឋាភិបាលបានបើកទូលាយឱ្យប្រជាពលរដ្ឋមានសិទ្ធិលើជំនឿសាសនា។ ការរីកចម្រើនខាងសម្ភារៈក៏មានសន្ទុះយ៉ាងលឿន។ ស្របពេលនោះ ការហូរចូលនូវវប្បធម៌ផ្សេងៗ តាមរយៈខ្សែភាពយន្ត និងពាណិជ្ជកម្មក៏មានច្រើនគួរឱ្យព្រួយបារម្ភ។ ការជូនពរគ្នានៅក្នុងឱកាសបុណ្យណូអែល និងចូលឆ្នាំសាកល យើងអាចធ្វើទៅបានតាមក្រសួងមន្ទីរ និងស្ថានទូតនានា ដើម្បីសម្តែងនូវមនោសញ្ចេតនា គួរសម និងការគោរពចំពោះជនមានជំនឿសាសនាដែលប្រារព្ធពិធីបុណ្យនេះ ដែលជាសុជីវធម៌របស់ខ្មែរ។ ប៉ុន្តែចំពោះប្រារព្ធ និងអបអរសាទរបុណ្យណូអែលនេះរបស់សិស្សានុសិស្ស យុវជន យុវនារី ដែលជួបជុំគ្នាជប់លៀង និងជូនអំណោយដល់គ្នាទៅវិញទៅមក អ្នកស្រីគង់ ណារី មិនមានការពេញចិត្តឡើយ ពីព្រោះខ្មែរយើងមានបុណ្យជាតិ និងប្រពៃណីគ្រប់គ្រាន់ ហើយសុទ្ធតែល្អៗទៀតផង។

អ្នកស្រីបានត្អូញត្អែរថា ទោះបីជាសាលារៀនបានហាមប្រាមយ៉ាងណាក៏ដោយ ក៏មិនមានប្រសិទ្ធភាពឡើយ ដោយអ្នកស្រីធ្វើការបញ្ជាក់ផងដែរថា មានសិស្សមួយចំនួនមានលុយច្រើនជាងលោកគ្រូ និងអ្នកគ្រូរបស់ពួកគេទៅទៀត។ ដូច្នេះបើយើងធ្វើការរឹតបន្តឹងខ្លាំង នឹងអាចបណ្តាលឱ្យមានបញ្ហាដល់លោកគ្រូ និងអ្នកគ្រូ ដោយសារមនុស្សមានកិលេសតណ្ហានៅក្នុងខ្លួន គឺទោសៈ មោហៈ និងលោភៈ ដែលធ្វើឱ្យសិស្សអាចធ្វើអំពើមិនគប្បីចំពោះលោកគ្រូ-អ្នកគ្រូខ្លួនឯង។ សាស្ត្រាចារ្យរូបនេះ ក៏បានធ្វើការអំពាវនាវដល់អាណាព្យាបាល សូមកាត់បន្ថយនូវការផ្តល់សម្ភារៈដល់កូន។ ក្នុងន័យនេះ អ្នកស្រីបញ្ជាក់ថា មិនមែនមិនចង់ឱ្យអាណាព្យាបាល ផ្តល់សម្ភារៈដល់កូនរបស់គេនោះឡើយ ប៉ុន្តែសូមកុំផ្តល់លើសពីសេចក្តីត្រូវការ និងតាមចំណង់ពួកគេពេក ដើម្បីកុំឱ្យគេមានសំអាង ភ្លេចការរៀនសូត្រ និងភ្លើតភ្លើនភ្លេចខ្លួន។ ម្យ៉ាងទៀត អ្នកស្រីក៏សំណូមពរដល់សាលានានា ចាប់ពីមត្តេយ្យរហូតដល់មហាវិទ្យាល័យ សូមកុំបន្តប្រារព្ធ ឬអបអរសាទរនៅក្នុងសាលាឡើយដើម្បីកុំឱ្យសិស្សវង្វេង ហើយនាំឱ្យវប្បធម៌របស់ខ្លួនធ្លាក់ចុះ។ យើងទាំងអស់គ្នាមានតួនាទីណែនាំយុវជន ឱ្យដើរលើផ្លូវត្រឹមត្រូវ ចេះយកចិត្តទុកដាក់ស្រលាញ់វប្បធម៌ និងប្រពៃណីទំនៀមទម្លាប់នៅលើទឹកដីរបស់ខ្លួន ដែលមានតម្លៃយ៉ាងសន្ធឹកសន្ធាប់មិនអាចកាត់ថ្លៃបាន ហើយសម្បូរបែបទៀតផង។


Photo: L. Samphors
អ្នកស្រីគង់ ណារី
សាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរ

**អត្ថបទដោយលោកលី សុវណ្ណា**





**ឆ្លៀតពេលសម្រាកពីការសិក្សានៅសាលារដ្ឋ សិស្សតូចៗជាច្រើនបានយកពេលវេលាសម្រាករបស់ពួកគេមកអង្គុយស្តាប់ការនិទានរឿងរបស់លោកគ្រូអ្នកគ្រូដែលមកពីអង្គការជេអេសស៊ី។ ការនិទានរឿងនេះមានសារៈសំខាន់ណាស់សម្រាប់ក្មេងៗទាំងនោះ ពីព្រោះវាអាចជួយឱ្យក្មេងៗបង្កើននូវចំណេះដឹងបន្ថែមទៀតបាន។**

# អប់រំកុមារតាមរយៈនិទានរឿង


សិស្សតូចស្តាប់ការនិទានរឿងរបស់អ្នកគ្រូដោយយកចិត្តទុកដាក់
Photo: H. Rann

ម៉ោងប្រមាណជា ៩ព្រឹក ក្រោមផ្ទៃមេឃស្រទុំដូចជាចង់ភ្លៀង នារដូវវស្សា ក្មេងៗជិត១០០នាក់ កំពុងរត់លេងនៅមុខសាលារបស់ខ្លួនយ៉ាងសប្បាយរីករាយ ។ ពួកគេក៏រង់ចាំលោកគ្រូអ្នកគ្រូរបស់គេដែលនឹងមកនិទានរឿងឱ្យពួកគេស្តាប់រៀងរាល់ថ្ងៃសុក្រ ។ "តោះពួកយើង លោកគ្រូ អ្នកគ្រូមកហើយ នាំគ្នាចូលក្នុងថ្នាក់" នេះគឺជាសំឡេងស្រែកយ៉ាងកងរំពងចេញពីមាត់កូនសិស្សតូចៗ ដែលមានអាយុចន្លោះពី៦-១៦ឆ្នាំ រៀននៅកម្រិតបឋមសិក្សា ។

ក្រោយពីសម្រាកពីការនិទានរឿងអស់រយៈពេលជាង ១ម៉ោង រួចមក អ្នកគ្រូធីតា មកពីអង្គការ ជេអេសស៊ី លើកឡើងថា : "យើងបានស្នើសុំសាលារដ្ឋដែលទំនេរពីម៉ោងសិក្សា ដើម្បីបំប៉នពួកគេលើកម្មវិធី ដូចជា អក្សរសាស្ត្រខ្មែរ និងគណិតវិទ្យា-ល-" ។ អ្នកគ្រូក៏បន្តទៀតថា កុមារទាំងនេះមកពីក្នុងភូមិជិតៗនេះ ហើយពួកគេពុំមានកម្រិតសិក្សាដូចគ្នាទេ គឺមានពីថ្នាក់ទី១ ដល់ថ្នាក់ទី៣ ។

កុមារី សុខអាន អាយុ១៣ឆ្នាំ រៀនថ្នាក់ទី៤ ក៏បាននិយាយថា : "ខ្ញុំចូលចិត្តកម្មវិធី ដែលរៀបចំឡើងដោយលោកគ្រូ អ្នកគ្រូនេះណាស់ ពីព្រោះខ្ញុំអាចស្តាប់រឿងល្អៗ ដែលពួកគាត់យកមកនិទានឱ្យយើងស្តាប់ ។" នាងក៏បន្ថែមទៀតថា នាងរៀនមិនសូវចេះទេនៅសាលារដ្ឋ ។ នៅទីនេះនាងរៀនចេះជាងដោយរៀនបានទៀងទាត់ ហើយមានការយកចិត្តទុកដាក់ពីលោកគ្រូអ្នកគ្រូ ។ នៅដៃកាន់សៀវភៅរឿងនិយាយពីភាពឆ្លាតវៃនៃកុមារតូច កុមារាសម្បត្តិ មិត្តរួមថ្នាក់របស់សុខអាន អាយុ១៥ឆ្នាំ រៀនថ្នាក់ទី៦នៅសាលារដ្ឋ ក៏បានចូលរួមស្តាប់ និងសិក្សា ក្នុងកម្មវិធីនៃអង្គការជេអេសស៊ីនេះផងដែរ ។ សម្បត្តិ បាននិយាយថា : "ខ្ញុំបានចូលរួមស្តាប់រឿងនៅទីនេះ រៀងរាល់ពេលមិនដែលឈប់ទេ ។" សម្បត្តិបញ្ជាក់ទៀតថា គេមករៀនទីនេះ និងស្តាប់រឿងនិទានរបស់អ្នកគ្រូ ។ គេក៏សប្បាយចិត្តណាស់ដែលអង្គការជេអេសស៊ីបានរៀបចំកម្មវិធីនេះឡើង ។


Photo: H. Rann
ការផ្តល់ចំណេះដឹងបន្ថែមដល់ក្មេងៗក្នុងថ្នាក់មួយក្រោមផ្ទះប្រជាពលរដ្ឋ

អ្នកស្រីចន្ទី គឺជាអ្នកម្តាយដែលមានអាយុ ៣៥ឆ្នាំ កំពុងអង្គុយនៅខាងក្រៅសាលាដើម្បីរង់ចាំកូនដែលចេញពីរៀន មានប្រសាសន៍ឱ្យដឹងថា : "កូនរបស់ខ្ញុំមិនបាត់មួយណាឡើយ ព្រោះពួកគេពេញចិត្តក្នុងការស្តាប់រឿងនិទាននេះណាស់ ។ ខ្ញុំបានឱ្យកូនទាំងពីរនាក់ មករៀនទីនេះ ។" គាត់ក៏បានបញ្ជាក់ទៀតថា កូនគាត់ទាំងពីរនាក់នេះមានចិត្តចង់រៀនណាស់ ។ ពួកគេពុំដែលខកខានមកស្តាប់ការនិទានរឿង និងមកសិក្សានៅទីនេះម្តងណាទេ ។ លោកគ្រូសន ខន មានប្រសាសន៍ឱ្យដឹងដែរថា លោកពុំមានការលំបាកនោះទេ ជាពិសេសនោះ នៅពេលណាដែលសិស្សទាំងអស់ដឹងថា អង្គការយើងមានកម្មវិធីនេះឡើង ។ ពួកគេមករៀនយ៉ាងច្រើន ជាពិសេស មានការចូលរួមយ៉ាងសកម្ម ពីប្រជាពលរដ្ឋ ពីព្រោះពួកគាត់មើលឃើញថាការអប់រំរបស់ពួកគេនៅមានកម្រិតខ្សោយនៅតាមសាលារដ្ឋ ពួកគាត់បានស្នើសុំឱ្យអង្គការជួយដល់កម្មវិធីអប់រំបំប៉ននេះ ។

អ្នកគ្រូកុលសៀប ជាអ្នកនិពន្ធសៀវភៅរឿងសម្រាប់ក្មេងៗ ប្រចាំនៅអង្គការជេអេសស៊ី បានមានប្រសាសន៍ឱ្យដឹងថា : "ការសំខាន់ដែលអង្គការមានកម្មវិធីនិទានរឿងនេះឡើងដោយហេតុថា កុមារទាំងនោះ មានអ្នកខ្លះមិនបានសិក្សា ដូច្នេះពួកគេមិនអាចចេះអាន និងមិនមានឱកាសស្តាប់រឿងនិទានឡើយ ។ ប៉ុន្តែសម្រាប់អ្នកចេះហើយ គឺយើងចង់ឱ្យគេបានយល់កាន់តែស៊ីជម្រៅទៅក្នុងរឿងនេះ ដោយយើងមានជាសំនួរសួរ និងឆ្លើយដល់គេ បន្ទាប់ពីគេបានស្តាប់ចប់ ។" អ្នកគ្រូបញ្ជាក់បន្ថែមទៀតថា ការងារក៏មានការជួបនូវការលំបាកខ្លះៗដែរ ដែលអង្គការយើងរៀបចំកម្មវិធីនេះឡើង ដោយតម្រូវទៅលើពេលវេលារបស់កុមារទាំងនោះ ដូចជាការណាត់ជួបពួកគេ ជួនកាលពួកគេបានទៅសាលារដ្ឋ និងពេលខ្លះនោះ ពួកគេក៏ជាប់រវល់ការងារជួយឪពុកម្តាយនៅផ្ទះជាដើម ។

**ហ៊ិន រ៉ាន់**

## សកម្មភាពក្រុម

សព្វថ្ងៃនេះ មានក្រុមការងារនេះដែលបម្រើសេវាកម្មនៅតាម ២១ភូមិ នៅក្នុងទីរួមខេត្តកំពង់ឆ្នាំង ខេត្តកណ្តាល និងខេត្តកំពង់ស្ពឺខាងផ្នែកបណ្ណាល័យ។ កម្មវិធីរបស់ក្រុមនេះបានចាប់ផ្តើមឡើងតាំងពីឆ្នាំ ២០០៥ ដែលមានការបង្កើតបណ្ណាល័យនៅតាមបណ្តាភូមិមួយចំនួននៅក្នុងខេត្តទាំងបីខាងលើនេះ សម្រាប់ឱ្យកុមារមានឱកាសច្រើនក្នុងការអានសៀវភៅផ្សេងៗដើម្បីបង្កើនចំណេះដឹងទូទៅ។ កម្មវិធីមានការជួយឧបត្ថម្ភពីក្រុមការងាររបស់អង្គការជេអេសស៊ីដូចជាមានការនិពន្ធសៀវភៅរឿងជាដើម។ ក្រៅពីការនិទានរឿងនៅតាមសាលាបឋមនានា មានពេលខ្លះ ការងាររបស់លោកគ្រូអ្នកគ្រូក៏មានធ្វើនៅក្រោមដើមឈើ និងផ្ទះរបស់អ្នកស្រុកផងដែរ។

December-2007.qxd 12/18/2007 3:54 PM Page 10



ភ្នំពេញ ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៨

## លិខិតអញ្ជើញ

**យើងខ្ញុំ គណៈកម្មាធិការអប់រំជំនឿ មនុស្សពេញវ័យអន្តរភូមិភាគ**
**សូមជម្រាបជូន**
**អស់លោកបូជាចារ្យ បព្វជិត បព្វជិតា**
**និងអស់បងប្អូនទទួលខុសត្រូវលើអ្នកណែនាំអប់រំជំនឿមនុស្សពេញវ័យ។**

**កម្មវត្ថុ** : មានសិក្ខាសាលាប្រចាំឆ្នាំសម្រាប់អ្នកអប់រំជំនឿមនុស្សពេញវ័យ ។ ពីថ្ងៃទី *១៤* (វេលាម៉ោង ៥ រសៀល) រហូតដល់ថ្ងៃទី *១៨* (វេលាម៉ោង ៩យប់) ខែ ***មករា*** ឆ្នាំ ***២០០៨*** នៅព្រះវិហារក្រុងព្រះសីហនុ ។

**គម្រោងការណ៍នៃសិក្ខាសាលា**



១.ចែកបទពិសោធន៏
២.រំឭកពីដំណាក់កាលនៃការអប់រំជំនឿមនុស្សពេញវ័យ
៣.បង្ហាញសៀវភៅថ្មីសម្រាប់អប់រំជំនឿមនុស្សពេញវ័យ
៤.រិះគិតអំពីការចាត់ចែង ការអប់រំអ្នកអប់រំជំនឿ

សូមអស់លោកអញ្ជើញចូលរួម និងសូមចាត់ចែងបងប្អូនដែលមានមុខងារអប់រំជំនឿនៅតាមព្រះសហគមន៍នីមួយៗ ចូលរួម តាមសេចក្តីត្រូវការ ។ សូមព្រះយេស៊ូគ្រីស្តជាអម្ចាស់គង់ជាមួយបងប្អូនគ្រប់ពេល!

គណៈកម្មាធិការអប់រំជំនឿមនុស្សពេញវ័យ អន្តរភូមិភាគ

**ហ្វ្រង់ស្វ័រ ប៉ុងសួដ៏**

បញ្ជាក់ :
-សូមផ្ញើចំនួនអ្នកចូលរួមមកយើងខ្ញុំ
មុនថ្ងៃទី ០១-០១-០៨
-សូមបងប្អូនយកព្រះគម្ពីរផ្ទាល់ខ្លួនមកផង ។

## ភូមិភាគភ្នំពេញជួបប្រជុំធ្វើការវាយតម្លៃការងារ

កាលពីថ្ងៃទី២១ វិច្ឆិកា ២០០៧ នៅព្រះសហគមន៍សន្តយ៉ូសែប ទីក្រុងភ្នំពេញ ក្រុមប្រឹក្សាព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានរៀបចំកិច្ចប្រជុំមួយ ដែលពិភាក្សាវាយតម្លៃលើសកម្មភាពប្រចាំថ្ងៃក្នុងនាមជាគ្រីស្តបរិស័ទ ។ ក្នុងអង្គប្រជុំនេះ មានតំណាងព្រះសហគមន៍ភូមិភាគភ្នំពេញចូលរួមទាំងអស់ ៣០នាក់ ។ កិច្ចប្រជុំនេះ បានឱ្យដឹងផងដែរថា នៅថ្ងៃទី៣០ មីនា ឆ្នាំ២០០៨ ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញនឹងរៀបចំប្រជុំបូកសរុបប្រចាំឆ្នាំ ដែលនឹងមានគ្រីស្តបរិស័ទចូលរួម ប្រមាណជា ៣០០០នាក់ ។ **កញ្ញា**



Photo: K. Kaghna

## សន្និសីទ ស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យ



Photo: L. Samphors

កាលពីថ្ងៃទី២៩ វិច្ឆិកា ឆ្នាំ២០០៧ កន្លងទៅនេះ នៅមជ្ឈមណ្ឌលវប្បធម៌បារាំង មានរៀបចំសន្និសីទមួយស្តីអំពីប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជានារបបកម្ពុជាប្រជាធិបតេយ្យ ដោយយោងតាមសៀវភៅកម្ពុជាឆ្នាំសូន្យ ដែលជាស្នាដៃនិពន្ធរបស់លោកហ្វ្រង់ស្វ័រ ប៉ុងសួដ៏ ។ ពិធីនេះមានការចូលរួមពីសំណាក់ភ្ញៀវជាតិ និងអន្តរជាតិ ដ៏ច្រើនកុះករ ។ លោកហ្វ្រង់ស្វ័រ ប៉ុងសួដ៏ ដែលជាវាគ្មិន មានប្រសាសន៏សង្កត់ធ្ងន់ថា: "បើយើងចង់បានអនាគតមួយដ៏ភ្លឺថ្លា យើងត្រូវទាមទារឱ្យមានយុត្តិធម៌ក្នុងសង្គម ។ បើគ្មានយុត្តិធម៌ក្នុងសង្គមនោះ យើងមិនអាចមើលឃើញអនាគតមួយដែលភ្លឺថ្លាឡើយ" ។ ""កម្ពុជាឆ្នាំសូន្យ" គឺជាចំណងជើងសៀវភៅមួយ ដែលលោកហ្វ្រង់ស្វ័រ ប៉ុងសួដ៏និពន្ធកាលពីឆ្នាំ១៩៧៦ ដោយនិយាយពីទុក្ខវេទនារបស់ជនជាតិខ្មែរ ដែលរងគ្រោះនៅក្នុងសម័យខ្មែរក្រហម ។ លោកជាជនបរទេសដែលធ្លាប់បានរស់នៅក្នុងរបបខ្មែរក្រហមអស់រយៈពេល ៣ សប្តាហ៍ផងដែរ ។ ដោយសារភាពល្បីល្បាញសៀវភៅនេះត្រូវបានបកប្រែ និងបោះពុម្ពជាចំនួនប្រាំបីភាសា ទាំងភាសាខ្មែរ ។ សៀវភៅនេះ គឺជាសារមួយប្រាប់មតិអន្តរជាតិឱ្យយល់ដឹងពីសម័យកាលមួយដ៏សែនឈឺចាប់បំផុតរបស់ប្រជាជនកម្ពុជា ។ **សម្ផស្ស**

**ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក :**
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧មករា រាជធានី ភ្នំពេញ
**Tel/Fax : (855) 23 224 120 ;**
**E-mail : csccambodia@gmail.com**
**Web: www.catholiccambodia.org**
**ក្រុមប្រឹក្សាភិបាល :** លោកអភិបាល អេមីល ដេតម្ប និងលោកអូមែរ ហ្សីរ៉ាល់ដូ ។
**ចាងហ្វាងការផ្សាយ :** លោកលី សុវណ្ណា ។

## ជួបជុំជាមួយប្រធានបងប្រុសសហគមន៍តេហ្សេនៅបារាំង



Photo: L. Samphors

ស្តាំ : បងប្រុសអាលូអ៊ីសមកពីសហគមន៍តេហ្សេបារាំង

កាលពីថ្ងៃរសៀល ទី២៩ វិច្ឆិកា នៅឯព្រះវិហារសន្តយ៉ូសែប យុវជនយុវនារីយ៉ាងកុះករ បានមកចូលរួមសិក្ខាសាលា និងអធិដ្ឋានជាមួយបងប្រុសអាលូអ៊ីសជាប្រធានក្រុមអ្នកបួសរបស់សហគមន៍តេហ្សេ នៅប្រទេសបារាំង ។ នេះជាលើកទី១សម្រាប់ព្រះសហគមន៍កាតូលិកនៅកម្ពុជា ដែលបងប្រុស បានមកធ្វើទស្សនកិច្ច និងលើកទឹកចិត្តដល់យុវជនយុវនារី នៅក្នុងជំនឿរបស់ខ្លួន ។ កម្មវិធីធ្វើឡើង ក្រោមប្រធានបទ "ជ្រើសរើសយកក្តីស្រឡាញ់ និងសង្ឃឹម" ។ បងប្រុសអាលូអ៊ីស បានថ្លែងថា នេះជាប្រធានបទដែលមានន័យថា វាជាការបញ្ចូលសន្តិភាពដែលព្រះយេស៊ូផ្តល់មកឱ្យយើង ។ **សុខធារី**

## ស្ត្រីលក់ស្រាបៀរមិនមែនជាអ្នករកស៊ីផ្លូវភេទ

**នេះជាខួបលើកទី ២៦នៃទិវាយុទ្ធនាការ ១៦ថ្ងៃប្រឆាំងអំពើហិង្សាលើស្ត្រី និងកុមារ ដែលប្រារព្ធធ្វើឡើងនាថ្ងៃទី៥ ធ្នូ នៅវត្តភ្នំ រាជធានីភ្នំពេញ។ ស្រីបម្រើស្រាបៀរប្រមាណជាង ១ពាន់នាក់ បានមកជួបជុំគ្នាក្នុងវេទិកាសាធារណៈស្តីអំពី "ស្ត្រីលក់ស្រាបៀរ និងការការពារផ្នែកច្បាប់" ដែលរៀបចំឡើងដោយអង្គការដើម្បីជួយស្ត្រីមានវិបត្តិ។ លោកស្រីណុប សារិនស្រីរ័ត្ន ប្រធានការងារសកម្មនៃអង្គការដើម្បីជួយស្ត្រីមានវិបត្តិ បានឡើងថ្លែងក្នុងអង្គវេទិកានោះថា គោលបំណងសំខាន់នៃទិវានេះគឺដើម្បីរំឭកខួបលើកទី២៦ នៃយុទ្ធនាការ ១៦ថ្ងៃប្រឆាំងអំពើហិង្សាលើស្ត្រី និងកុមារ ហើយផ្តល់ការអប់រំឱ្យប្រជាជនយល់ដឹងពីស្ថានភាពស្ត្រីបម្រើស្រាបៀរ និងលុបបំបាត់ចោលនូវទស្សនៈនៃការរើសអើងថាស្ត្រីបម្រើស្រាបៀរជាស្ត្រីរកស៊ីផ្លូវភេទ។ ជាមួយនោះលោកជំទាវជូ ប៊ុនអេង អគ្គលេខាធិការនៃក្រសួងអភិវឌ្ឍន៏សង្គមនៃក្រសួងកិច្ចការនារី មានមតិផ្តែផ្តាំទៅកាន់នារីបម្រើស្រាបៀរទាំងអស់ថា : "ទិវានៅថ្ងៃនេះមិនមែនមានន័យថា អាចបញ្ចប់នូវការរើសអើងក៏ដូចជាបញ្ឈប់អំពើហិង្សានោះទេ គឺវាគ្រាន់តែជាការផ្សព្វផ្សាយជូនសាធារណជនឱ្យបានដឹង"។ លោកជំទាវបន្ថែមទៀតថា ទោះបីជាស្ត្រីខ្មែរស្ថិតនៅក្នុងការងារបែបណាក៏ដោយ គឺត្រូវរក្សានូវឥរិយាបថ តម្លៃរបស់ខ្លួន ហើយត្រូវការពារ និងរក្សានូវតម្លៃរបស់ខ្លួនយើងឱ្យបានត្រឹមត្រូវ។ កញ្ញាអន ស្រីណា អាយុ២០ឆ្នាំ ដែលបានចូលរួមនៅក្នុងទិវានោះបានប្រាប់ថា ការដែលគេនិយាយថា អ្នកបម្រើសាបៀរមិនល្អនោះ គឺមកពីគេយល់មិនទាន់ដល់ ប៉ុន្តែចំពោះអ្នកដែលគេដឹងច្បាស់ គឺវាជាការងារធម្មតាមួយដែលមានភាពត្រឹមត្រូវដូចការងារដទៃទៀតដែរ។ ស្រីណាបន្តថា "ពេលយប់ ខ្ញុំជាស្រីបម្រើស្រាបៀរ តែពេលថ្ងៃខ្ញុំជាមនុស្សធម្មតា"។ អាគីប**



Photo: M. Kunthear



### អធិប្បាយព្រះបន្ទូល

## បុណ្យព្រះយេស៊ូប្រសូត

**ថ្ងៃអង្គារ ទី២៥ ធ្នូ ឆ្នាំ២០០៧:** **ថ្ងៃបុណ្យលើកតម្កើងព្រះយេស៊ូប្រសូត** *"ព្រះបន្ទូលកើតជាមនុស្សហើយរស់នៅជាមួយយើង"* **(យ៉ូហាន ១,១៤)** ។ តាមគម្ពីរ មានរៀបរាប់អំពីព្រះយេស៊ូប្រសូតយ៉ាងអស្ចារ្យ ។ មានទេវទូតយាងចុះពីស្ថានបរមសុខ និងច្រៀង-ល- ។ អ្នកនិពន្ធតែងរបៀបនេះក៏មិនសូវប្លែកពីពុទ្ធបរិស័ទរៀបរាប់អំពីព្រះពុទ្ធប្រសូតទេ ។ របៀបនិពន្ធទាំងនេះសុទ្ធតែជានិមិត្តរូបបញ្ជាក់អំពីឋានៈទារកដែលទើបកើត ។ តាមជំនឿអ្នកនិពន្ធ និងគ្រីស្តបរិស័ទ លោកយេស៊ូដែលទទួលជីវិតថ្មីដ៏រុងរឿង គឺព្រះជាម្ចាស់បានប្រោសលោកយេស៊ូដែលគេបានឆ្កាង ឱ្យក្រោកពីចំណោមមនុស្សស្លាប់ និងតែងតាំងលោក ជាព្រះគ្រីស្ត និងជាព្រះអម្ចាស់! ។ ពេលយើងនាំគ្នាធ្វើបុណ្យព្រះយេស៊ូប្រសូត យើងត្រូវនឹកសញ្ជឹងពីអត្ថន័យដ៏ជ្រាលជ្រៅនៃអត្ថបទនេះ គឺថានៅពេលព្រះយេស៊ូប្រសូត គឺព្រះជាម្ចាស់ដូចជាបើកទ្វារស្ថានបរមសុខឱ្យមនុស្សយើងទាក់ទងជាមួយព្រះអង្គ ។ ព្រះយេស៊ូដូចជាស្ពានមេត្រីរវាងព្រះជាម្ចាស់ និងមនុស្សលោកយើង ដូចសន្តអ៊ីរេណេ ជាអភិបាលពីជំនាន់ដើមថ្លែងថា : "ព្រះជាម្ចាស់ប្រសូតជាមនុស្សដើម្បីមនុស្សទៅជាព្រះជាម្ចាស់វិញ" ។ ព្រះអង្គប្រោសឱ្យយើងទៅជាបុត្រធីតារបស់ព្រះអង្គ ។ ដូច្នេះជីវិតមនុស្សម្នាក់ៗ សុទ្ធតែមានតម្លៃថ្លៃថ្នូរ ។



**ថ្ងៃអាទិត្យ ទី៣០ ធ្នូ ឆ្នាំ២០០៧:** **បុណ្យលើកតម្កើងព្រះរាជវង្ស** *"យើងបានត្រាស់ហៅបុត្រយើងពីស្រុកអេស៊ីបមក"* **(ម៉ាថាយ ២,១៣-១៥ &១៩-២៣)** ។ តើព្រះយេស៊ូមានឋានៈជានរណា ? ក្រោយពីព្រះជាម្ចាស់ប្រោសលោកយេស៊ូឱ្យក្រោកពីចំណោមមនុស្សស្លាប់ទទួលព្រះជន្មថ្មីដ៏រុងរឿង សាវ័កព្រះអង្គក៏យកចិត្តទុកដាក់រិះគិតអំពីឋានៈ និងពីបេសកកម្មព្រះយេស៊ូ ។ ពួកគេក៏យល់ឃើញថា ព្រះយេស៊ូយាងមកប្រទានធម្មវិន័យថ្មីឱ្យអ្នកជឿលើព្រះអង្គ និងយាងមកចងសម្ព័ន្ធមេត្រីថ្មី ឱ្យមនុស្សមានទំនាក់ទំនងថ្មីជាមួយនឹងព្រះជាម្ចាស់ ។ ដូច្នេះគេប្រៀបធៀបព្រះយេស៊ូនឹងលោកម៉ូសេដែលតែងតាំងសាសនារបស់គេពីដើម ។ ហេតុនេះអ្នកនិពន្ធគម្ពីរពន្យល់ថា មាតាបិតានៃព្រះយេស៊ូនាំព្រះអង្គភៀសខ្លួនទៅស្រុកអេស៊ីប រួចវិលត្រឡប់មកវិញ ដូចប្រជាជនអ៊ីស្រាអែលពីដើមទៅនៅស្រុកអេស៊ីប រួចត្រឡប់ទៅស្រុករបស់ខ្លួននៅជំនាន់លោកម៉ូសេដែរ ។ អ្នកនិពន្ធព្រះគម្ពីរចង់ពន្យល់ថា ព្រះយេស៊ូរួមសាមគ្គីជាមួយប្រជារាស្ត្ររបស់ព្រះជាម្ចាស់ក្នុងគ្រប់វិស័យ ដូច្នេះព្រះអង្គពិតជាសង្គ្រោះគេ ។



យើងជាគ្រីស្តបរិស័ទកម្ពុជា ក៏ត្រូវយកចិត្តទុកដាក់ពន្យល់ជំនឿខ្លួន តាមអរិយធម៌ខ្មែរដូចលោកម៉ាថាយពីដើម ពន្យល់ជំនឿរបស់ព្រះសហគមន៏តាមអរិយធម៌អ៊ីស្រាអែលពីដើមដែរ ។ ព្រះអង្គប្រៀបដូចព្រះពុទ្ធជាព្រះបរមគ្រូ ដែលបានអប់រំប្រជាជនជាច្រើនអនេកនៅទ្វីបអាស៊ីយើង ។

**ថ្ងៃអាទិត្យ ទី៦ មករា ឆ្នាំ២០០៨ :** **ថ្ងៃលើកតម្កើងព្រះយេស៊ូដែលសម្តែងឋានៈរបស់ព្រះអង្គឱ្យមនុស្សលោកស្គាល់** *"យើងខ្ញុំបានឃើញផ្កាយរបស់ព្រះអង្គ"* **(ម៉ាថាយ ២,១-១២)** ។ លោកម៉ាថាយជាអ្នកនិពន្ធអត្ថបទគម្ពីរនេះ ចង់ពន្យល់សភាពការណ៏នៃព្រះសហគមន៏របស់លោកថា ហេតុអ្វីបានជាជនជាតិយូដាជាជាតិសាសន៏របស់ព្រះយេស៊ូមិនជឿលើព្រះយេស៊ូជាព្រះគ្រីស្ត រីឯសាសន៏ដទៃនាំគ្នាជឿទៅវិញ? ហេតុនេះបានជាលោក តែងរឿងមួយស្តីអំពីហោរាជាសាសន៏ដទៃជាអ្នកខិតខំស្វែងរកសេចក្តីពិត ។ ពេលគេឃើញនូវសញ្ញាសម្គាល់ គឺផ្កាយជានិមិត្តរូបអំពីព្រះគ្រីស្ត គេក៏ចេញដំណើរមកថ្វាយបង្គំព្រះអង្គ ។ រីឯជនជាតិយូដា ទោះបីជាប្រជារាស្ត្រដែលព្រះជាម្ចាស់បានជ្រើសរើសក្តី មិនព្រមចេញដំណើរទៅរកព្រះអង្គវិញ ។ គេស្មានថា ខ្លួនគេមានគ្រប់គ្រាន់ហើយ មិនត្រូវការប្រែចិត្តគំនិតទេ ។



រឿងនេះក៏ជារឿងព្រះសហគមន៏យើងដែរ មានតែអ្នកដែលស្វែងរកព្រះគម្ពីរដោយឥតឈប់ឈរទេ ទើបអាចស្គាល់ព្រះអង្គបាន រីឯគ្រីស្តបរិស័ទដែលតែងស្មានថាខ្លួនមានជំនឿល្មមគ្រប់គ្រាន់ហើយ ឬជាមនុស្សល្អគ្រប់គ្រាន់ហើយ គឺប្រៀបបីដូចជនជាតិយូដាដែលមិនស្វែងរកព្រះគ្រីស្តទេ ។ ដូច្នេះយើងត្រូវតែស្វែងរកព្រះគ្រីស្តជានិច្ច ។

**ថ្ងៃអាទិត្យ ទី១៣ មករា ឆ្នាំ២០០៨ :** **ថ្ងៃលើកតម្កើងព្រះយេស៊ូទទួលពិធីជ្រមុជទឹក** *"លោកនេះគឺជាបុត្រដ៏ជាទីស្រឡាញ់របស់យើង យើងគាប់ចិត្តនឹងលោកណាស់"* **(ម៉ាថាយ ៣,១៣-១៧)** ។ ព្រះយេស៊ូទទួលពិធីជ្រមុជទឹកពីលោកយ៉ូហានបាទីស្តនៅគ.ស២៧ ។ តែគ្រីស្តបរិស័ទដើមដំបូង និងអ្នកនិពន្ធគម្ពីរដំណើងល្អរៀបរាប់ព្រឹត្តិការណ៏នេះ ទុកជាពេលលោកយេស៊ូត្រាស់ដឹងថាខ្លួនលោកជាព្រះគ្រីស្តផង និងទុកជាពិធីអភិសេកលោកយេស៊ូជាព្រះគ្រីស្តផងដែរ ។ អ្នកនិពន្ធចង់ពន្យល់អំពីឋានៈ និងបេសកកម្មរបស់ព្រះយេស៊ូដូចគេស្គាល់នៅពេលក្រោយ ។ ព្រះយេស៊ូដែលអ្នកស្រុកស្គាល់ទុកជាពលរដ្ឋធម្មតាតែព្រះអង្គជាព្រះបុត្រានៃព្រះជាម្ចាស់ ព្រះអង្គយាងមកបូជាព្រះជន្ម ដូចលោកអ៊ីសាកជាកូនដ៏ជាទីស្រឡាញ់របស់លោកអាប្រាហាំ និងដូចអ្នកបម្រើដែលព្រះជាម្ចាស់គាប់ព្រះហឫទ័យដែរ ។



យើងជាគ្រីស្តបរិស័ទសព្វថ្ងៃ ក៏ត្រូវផ្ញើជីវិតទាំងស្រុងលើព្រះយេស៊ូជាព្រះគ្រីស្តដែលបានបូជាព្រះជន្មដោយព្រះហឫទ័យស្រឡាញ់ព្រះបិតាក្នុងនាមយើង ។ មានតែព្រះយេស៊ូមួយព្រះអង្គគត់ដែលអាចណែនាំយើងឱ្យមានទំនាក់ទំនងជាមួយព្រះបិតាបាន ។

**លោកបូជាចារ្យហ្វ្រង់ស្វ័រ ប៉ុងសួដ៏**

December-2007.qxd 12/18/2007 3:54 PM Page 12



# ពុយ សាវ៉ង់ : "ការព្យាយាមតែងទទួលបាននូវជោគជ័យ"



Photo: H. Sokhtheary

**លោកពុយ សាវ៉ង់ មានស្រុកកំណើតនៅខេត្តក្រចេះ។ ឪពុកជាគ្រូបង្រៀន និងម្ដាយជាកសិករ។ លោកបានមករៀនមហាវិទ្យាល័យនៅភ្នំពេញ។ ថ្មីៗនេះ លោកជិតឈានទៅទទួលអាហារូបករណ៍នៅប្រទេសជប៉ុន។**

ក្នុងវ័យ២២ឆ្នាំ លោកពុយ សាវ៉ង់ បានសម្រេចកិច្ចការមួយដ៏ប្រសើរសម្រាប់ជាកិត្តិយសដល់គ្រួសារដែលមិនមានលទ្ធភាពផ្ដល់អ្វីទៅឱ្យកូនក្រៅតែពីចំណេះដឹងទេនោះ ។ ក្នុងគ្រួសារ លោកជាកូនទី៤ ដែលមាននិស្ស័យស្រឡាញ់ការសិក្សា ក្នុងចំណោមបងប្អូន៦នាក់ ។ យុវជនរូបនេះ បានទទួលអាហារូបករណ៍ បន្ទាប់ពីបានជាប់សញ្ញាប័ត្រទុតិយភូមិ ( បាក់ឌុប ) មក ។ លោកបានចូលរៀនថ្នាក់បរិញ្ញាប័ត្រផ្នែកគ្រប់គ្រងពាណិជ្ជកម្មនៅក្នុងសកលវិទ្យាល័យជាតិគ្រប់គ្រង ទីក្រុងភ្នំពេញ ។

ដៃកាន់សៀវភៅភាសាជប៉ុន អង្គុយក្នុងបន្ទប់វិបសាយក្រោមផ្ទៃមុខរីករាយ លោកពុយ សាវ៉ង់ ហាក់ទើបតែទទួលបានជោគជ័យអ្វីមួយ ដែលលោកបានប៉ងប្រាថ្នាជាយូរមកហើយ ។ ជាមួយនឹងស្នាមញញឹមយ៉ាងស្រស់ សាវ៉ង់ បានមានប្រសាសន៍ឱ្យដឹងថា : "ខ្ញុំសង្ឃឹមយ៉ាងមុឹងម៉ាត់ថា នឹងទទួលបានអាហារូបករណ៍ទៅរៀននៅប្រទេសជប៉ុន នៅឆ្នាំ២០០៨ខាងមុខនេះ" ។ លោកបន្តថា លោកសង្ឃឹម៩០% ថា នឹងទទួលបានជោគជ័យក្នុងកិច្ចការដែលលោកបានព្យាយាមជាច្រើនឆ្នាំមកនេះ ។ នេះជាដំណាក់កាលចុងក្រោយ ។ គេជម្រុះចេញតែ ២ នាក់ ក្នុងចំណោមអ្នកប្រកួតប្រជែងចំនួន ១៤នាក់ ។

យុវជនរូបនេះ បានបន្តឱ្យដឹងទៀតថា ការដែលលោកចង់ទៅសិក្សានៅបរទេស ព្រោះលោកអាចទទួលបានចំណេះដឹងទូលំទូលាយ និងជាពិសេសមានឱកាសបានរៀន ជាមួយនឹងនិស្សិតមកពីបណ្ដាប្រទេសផ្សេងៗ ជាច្រើនដើម្បីអាចដឹងអំពីសមត្ថភាពរបស់ខ្លួន និងប្រកួតជាមួយនឹងនិស្សិតប្រទេសទាំងនោះ ។ "មុខវិជ្ជាដែលខ្ញុំចង់រៀន គឺថ្នាក់អនុបណ្ឌិត ទំនាក់ទំនងអន្តរជាតិ ប៉ុន្តែកម្មវិធីនេះ ខ្ញុំមិនទាន់ដឹងច្បាស់ថា ខ្ញុំបានរៀនផ្នែកនេះ ឬអត់នោះទេព្រោះឆ្នាំដំបូងគឺខ្ញុំរៀនភាសាជប៉ុនបន្ថែម ១ឆ្នាំ ក្រោយមកទើបប្រលង ប្រសិនខ្ញុំជាប់នោះ ទើបខ្ញុំអាចចាប់យកមុខវិជ្ជានោះបាន ។" លោកពុយ សាវ៉ង់ និយាយ ។ លោកបានដឹង កម្មវិធីអាហារូបករណ៍ តាមមហាវិទ្យាល័យជាតិគ្រប់គ្រងដោយសារអង្គការ JICA មានកម្មវិធីនេះជាមួយសាលារួចជាស្រេច ។ ពេលនោះលោកក៏បានដាក់ពាក្យប្រឡងតែម្ដង ។

លោកពុយ សាវ៉ង់ បានប្រាប់ឱ្យដឹងអំពីការព្រួយបារម្ភក្នុងពេលប្រលងថា : "ដំបូងការប្រលងរបស់ខ្ញុំ ពិបាកដោយសារវាជាភាសាជប៉ុនសុទ្ធ ហើយខ្ញុំចេះ មិនទាន់មានកម្រិតខ្ពស់ប៉ុន្មាននៅឡើយ ។ ហេតុដូច្នេះនៅពេលប្រលង ខ្ញុំភ័យ និងខ្លាចធ្លាក់ព្រោះខ្ញុំធ្វើមិនបានល្អ ។ តែលទ្ធផលដែលលោកទទួលបានគឺជោគជ័យ" ។

ក្នុងការសិក្សា លោកសាវ៉ង់ ជួបប្រទះការលំបាកផ្នែកថវិកាច្រើន ដើម្បីទិញសៀវភៅធ្វើការស្រាវជ្រាវ និងមេរៀនខ្លះ ចាំបាច់ត្រូវតែស្រាវជ្រាវតាមអ៊ីនធឺណេត ។ សាវ៉ង់ហាក់ដូចជាអស់សំណើចនឹងខ្លួនឯង ដោយលោកបញ្ចប់បរិញ្ញាបត្រ ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម តែលោកបែរមានគម្រោងទៅរៀនមុខវិជ្ជាទំនាក់ទំនងអន្តរជាតិនៅជប៉ុន ស្ដាប់ទៅដូចជាឆ្គងបន្តិច ។ ប៉ុន្តែលោកគិតថា ដើម្បីទំនាក់ទំនងល្អជាមួយដៃគូពាណិជ្ជកម្ម យើងត្រូវតែដឹងពីវិធីសាស្ត្រក្នុងការទំនាក់ទំនង ទើបធ្វើឱ្យអាជីវកម្មរបស់យើងដំណើរការទៅបានល្អ ។ នេះគឺជាហេតុដែលលោកមានគម្រោងទៅអនាគត បើមានលទ្ធភាពគឺលោក នឹងប្រកបអាជីវកម្មតូចមួយ ប៉ុន្តែបើមិនអាចលោកចង់ធ្វើការនៅស្ថានទូតជប៉ុន ។

ដោយរំភើបចិត្ត លោកសាវ៉ង់និយាយថា: "ម្ដាយរបស់ខ្ញុំប្រាប់ថា គាត់គ្មានទ្រព្យសម្បត្តិអ្វី ចែកកូននោះទេ គឺមានតែការសិក្សាប៉ុណ្ណោះ ។ ចូរកូនខំរៀន! ។ ប៉ុន្តែព្រះសហគមន៍កាតូលិកឧបត្ថម្ភ ៥៥ដុល្លារ ជារៀងរាល់ខែ ។ ប្រសិនបើគ្មានជំនួយនេះទេ ការសិក្សារបស់ខ្ញុំគឺធ្លាក់ចុះខ្លាំង ពីព្រោះអំឡុងពេលដែលខ្ញុំស្នាក់នៅទីក្រុងភ្នំពេញ រាល់ការចាយវាយទាំងអស់ពឹងលើប្រាក់ទាំងនេះ ។"

លោកសាវ៉ង់មិនដែលគិតពីរឿងស្នេហា ឬសង្សារនោះទេ ព្រោះលោកគិតថា មានសង្សារ ត្រូវការមានលុយ និងពេលវេលាច្រើន សម្រាប់គេ ។ ប៉ុន្តែលោកចង់មានមិត្តភ័ក្ដ្រដែលចូលចិត្តរៀន និងមិនដែលគិតចង់បានមិត្តភ័ក្ដ្រដែលនាំលោកឱ្យដើរក្នុងផ្លូវមិនល្អដែរ ។

**ញ៉ូ សុខធារី និងអាគីប**

## គម្រោងការប្រចាំខែ

- **ថ្ងៃទី២១ ធ្នូ ឆ្នាំ២០០៧ :** ខួបតែងតាំងជាបូជាចារ្យរបស់លោកអេមីល ដេតម្ប អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ នៅព្រះវិហារសន្តយ៉ូសែប-រាជធានីភ្នំពេញ។
- **ថ្ងៃទី២២ ធ្នូ ឆ្នាំ២០០៧ :** សំណាក់ធម៌រិះគិតពីព្រះបន្ទូលនៅព្រះសហគមន៍ជុំគីរី។
- **ថ្ងៃទី២២ ធ្នូ ឆ្នាំ២០០៧ :** ពិធីសម្រុះសម្រួលរួមនៅព្រះសហគមន៍សន្តយ៉ូសែប ។
- **ថ្ងៃទី២៣ ធ្នូ ឆ្នាំ២០០៧ :** ភ្ញៀវមកពីហុងកុងចូលរួមបុណ្យណូអែលនៅព្រះសហគមន៍កាតូលិកកោះរកា ភូមិភាគកំពង់ចាម។
- **ថ្ងៃទី២៣-២៥ ធ្នូ ឆ្នាំ២០០៧ :** បុណ្យព្រះយេស៊ូប្រសូតនៅតាមព្រះសហគមន៍កាតូលិកនានានៅក្នុងខេត្តកំពត។
- **ថ្ងៃទី២៤ ធ្នូ ឆ្នាំ២០០៧ :** បុណ្យព្រះយេស៊ូប្រសូតនៅព្រះសហគមន៍សន្តយ៉ូសែប។
- **ថ្ងៃទី២៥-៣០ ធ្នូ ឆ្នាំ២០០៧ :** ទស្សនកិច្ចរបស់សប្បុរសជនសិង្ហបុរីនៅព្រះសហគមន៍កាតូលិកខេត្តសៀមរាប។
- **ថ្ងៃទី២៩ ធ្នូ ឆ្នាំ២០០៧ :** ប្រជុំគណៈកម្មការទាំងបីរបស់ព្រះសហគមន៍សន្តយ៉ូសែប។

**ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក** មានបម្រើសេវាកម្មបំប្លែងពីកាសែតវីដេអូ VHS ទៅ VCD និង DVD។ បំប្លែងពីកាសែតម៉ាញ៉េទៅជា CD និង MP3 និងមានទទួលធ្វើការថតចម្លង CD VCD និងDVD គ្រប់ប្រភេទ។ គ្រប់សេវាកម្មនឹងធ្វើក្នុងតម្លៃសមរម្យ។ សូមទំនាក់ទំនងតាមអាសយដ្ឋាន ឬទូរស័ព្ទ : ០១២ ៣៧៧ ៩៦០។

**សេចក្ដីជូនដំណឹង**

***"ផ្សព្វផ្សាយដំណឹងជ្រើសរើសបុគ្គលិកដោយគិតតម្លៃសមរម្យ"***

គ្រប់អង្គការ ក្រុមហ៊ុននិងស្ថាប័នទាំងអស់ ដែលមានបំណងចង់ផ្សព្វផ្សាយពាណិជ្ជកម្មផ្សេងៗ និងដំណឹងជ្រើសរើសបុគ្គលិកក្នុងតម្លៃទាប និងចំណេញច្រើន សូមទាក់ទងមកកាន់ការិយាល័យ **អ្នកនាំសារ** ដែលមានទីតាំងឋិតនៅផ្ទះលេខ ២៥ ផ្លូវ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧មករា ភ្នំពេញ ឬទូរស័ព្ទលេខ ០៩២ ៧៣៧ ២៥៥ ។

***បញ្ជាក់*** : គ្រប់ដំណឹងផ្សព្វផ្សាយ ឬជ្រើសរើសបុគ្គលិករបស់អង្គការ ក្រុមហ៊ុន ឬស្ថាប័ន ដែលគ្មាន Logo យើងនឹងផ្សាយដោយមិនគិតថ្លៃ ។